មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០៧ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនចំពោះឯកឧត្តមចំនួន ០២ រូប ១១០៥

០៥-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក **ខ្ទិម ចំរើន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ១១០៦

០៥-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០៩ ស្តីពីការប្រោសព្រះរាជទានចំពោះជនបរទេសចំនួន ០៣ រូប នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១១០៧

០៥-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១០ ស្តីពីការធ្វើសមាហរណកម្មក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី និង អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការ ចំនួន ០៧ រូប ១១០៨

០៨-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១២ ស្តីពីការតែងតាំងឯកឧត្តម **សួន សិទ្ធិ** ជា ឧកញ៉ា ១១១០

០៨-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៣ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៥ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ ១១១១

១០-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៥ ស្តីពីការកែសំរួលមាត្រា ២ ជំពូក ទី ១ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ដោយលុបត្រង់វាក្យខណ្ឌ :"ស្ថងការពិសេសការពារបេតិកភ័ណ្ឌនៃក្រសួងមហាផ្ទៃអនុវត្តភារកិច្ចរបស់ខ្លួនក្នុងតំបន់ អង្គរ ដោយសហការជាមួយអាជ្ញាធរ ខេត្តសៀមរាប" ។ ១១១៣

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៦ ស្តីពីការតែងតាំងលោកស្រី **ឈាង គីមស៊ុន** ជា ឧកញ៉ា ១១១៥

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៧ ស្តីពីការតែងតាំងឯកឧត្តមវេជ្ជបណ្ឌិត **ឡុក ចយ** ជាទីប្រឹក្សា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើរដ្ឋលេខាធិការ ១១១៦

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៨ ស្តីពីការតែងតាំងលោក **ខុឡី ទៅរ៍** ជា ឧកញ៉ា ១១១៧

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៩ ស្តីពីការតែងតាំងមុខតំណែងជូនឯកឧត្តមឧត្តម
សេនីយ៍ឯក **ម៉ូ លីដា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១១១៨

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០២០ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម
ម៉ិច សុខិន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១១១៩

១២-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០២១ ស្តីពីការប្រោសព្រះរាជទានចំពោះលោកជំទាវ
សារ៉ាម ចំនួមថ្ងៃ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១១២០

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៦-០១-២០០៧ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ១១២១

២៦-០១-២០០៧ -អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៣៩

២៦-០១-២០០៧ -អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៤០

២៦-០១-២០០៧ -អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១១៤១

២៩-០១-២០០៧ -អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ១១៤២

២៩-០១-២០០៧ -អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ១១៤៥

២. សេចក្តីសំរេច

២៥-០១-២០០៧ -សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការកែសំរួលសេចក្តីសំរេច ស្តីពីការបង្កើតក្រុមការងារ
តាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ១១៤៩

III. ការិយាល័យ/ក្រសួង

១. ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-១២-២០០៦ -ប្រកាសលេខ ១៤១៥ សហវ.ហក ស្តីពីការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែល
នៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាល ក្នុងការពិនិត្យសំរេចចុះទិដ្ឋាការលើ
លិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ ១១៥៧

៣០-១២-២០០៦ -ប្រកាសលេខ ១៤១៦ សហវ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅ របស់រដ្ឋ
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ១១៦១

៣០-១២-២០០៦ -ប្រកាសលេខ ១៤១៧ សហវ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូក
តាមគណនី អនុគណនី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ១១៩៣

០៥-០១-២០០៧ -ប្រកាសលេខ ០០១ សហវ.គរ ស្តីពីការកែសម្រួលអត្រាពន្ធគយ និង អត្រាអាករពិសេសលើទំនិញនាំចូលមួយចំនួន ១២០៨

១៧-០១-២០០៧ -ប្រកាសលេខ ០៩៨ សហវ ស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬអាយុជីវិត ១២១០

១៩-០១-២០០៧ -ប្រកាសអន្តរក្រសួងលេខ ១០០ សហវ.ប្រក ស្តីពីការគ្រប់គ្រងរថយន្តចង្កូតស្តាំ ដែលមានស្រាប់នៅក្នុងប្រទេស ១២២០

២៣-០១-២០០៧ -សេចក្តីណែនាំលេខ ០០២ សហវ ស្តីពីភារកិច្ច និងការទទួលខុសត្រូវរបស់ប្រធាន និងសមាជិកក្រុមការងាររបស់គណៈកម្មការអន្តរក្រសួង ១២២៣

១៩-០១-២០០៧ -សេចក្តីជូនដំណឹងលេខ ០០២សហវ.ពដ ស្តីពីភារកិច្ចបង់ពន្ធប៉ាតង់ ១២២៦

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

២២-០១-២០០៧ -ប្រកាសលេខ ១៣៦ អយក.ប្រក ស្តីពីការបើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការ មធ្យមសិក្សាទុតិយភូមិ ខេត្តកោះកុង ១២២៧

២២-០១-២០០៧ -ប្រកាសលេខ ១៣៧ អយក.ប្រក ស្តីពីការបើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការ មធ្យមសិក្សាទុតិយភូមិ រាជធានីភ្នំពេញ ១២២៩

២២-០១-២០០៧ -ប្រកាសលេខ ១៣៨ អយក.ប្រក ស្តីពីការបើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការ មធ្យមសិក្សាទុតិយភូមិ ខេត្តសៀមរាប ១២៣១

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចុង ជាន គំង យេ ម៉ៅ យី** ១២៣៣

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូរ៉ាឌី** ១២៣៥

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីង ហ្គោត អ៊ិនវេសមេន** ១២៣៧

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់ ស៊ីធី កាស៊ីណូ ហូថែល** ១២៣៩

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហួឈាន ខេម គ្រេឌីង ខូ អិលធីឌី** ១២៤១

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាប់បែលយូ ដាប់បែលយូ តី & ជី** ១២៤៣

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីន អ៊ិនធើណេសិនណល** ១២៤៥

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាន ម៉ាឌី គ្រុប** ១២៤៧

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិមអេច ឆាយអូ-អេនើជី គ្រុប** ១២៤៩

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភាំទើក អិលធីឌី** ១២៥១

២៤-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៧០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ខ្វី (ខេមបូឌា)** ១២៥២

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

-ឯកឧត្តម ឧត្តមសេនីយ៍ឯក ណឹម សុវត្ថិ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

-ឯកឧត្តម ហាំង ស៊ីថា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០១.០០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក ឱម ចំរើន អត្តលេខ ០០៨២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព.ល.០៧០១.០០៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៧

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

១-H.E Mr. LEE EUI-GEUN

២-H.E Mr. KIM KWAN-YONG

៣-H.E Mr. BAEK SANG-SEUNG

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/៧.០៧០១.០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៤ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបទូលបង្គំថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានធ្វើសមាហរណកម្មក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការ ចំនួន ០២ នាក់ ដូចមានរាយនាមខាងក្រោម :

១-លោកជំទាវ **មាន សំអាន** ឋានន្តរស័ក្តិ **ឧត្តមមន្ត្រី** ថ្នាក់លេខ ៣
២-លោកជំទាវ **ឈូក ឈីម** ឋានន្តរស័ក្តិ **ឧត្តមមន្ត្រី** ថ្នាក់លេខ ៣

មាត្រា ២ : ត្រូវបានធ្វើសមាហរណកម្មក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការ ចំនួន ០៥ នាក់ ដូចមានរាយនាមខាងក្រោម :

១ - លោក **ឡាយ ឧត្តម** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១១
២ - លោក **អ៊ិច តារា** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១២
៣ - លោក **ទ្រី ណារិន** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៣
៤ - លោក **ហ៊ិល នួច** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤
៥ - លោក **លឹម ស៊ុយសុទត្ថា** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៥

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០១.០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០០៧

លេខ : ៣០ ច.ល
សំរាប់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល.

ស៊ុន ចិនអេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

ឯកឧត្តម **ស៊ួន សិទ្ធី**

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៧០១.០១២

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៥ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧
[illegible]រាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បំពាក់ គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៥រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-នាយឧត្តមសេនីយ៍ផ្កាយមាស ៤ **នាង ផាត** អត្តលេខ ០០០០៨០

២-ឧត្តមសេនីយ៍ឯក **ហ៊ីន ធឿន** អត្តលេខ ០០០១៨៥

៣-ឧត្តមសេនីយ៍ឯក **ផាន់ ទូន** អត្តលេខ ០០០០៤៩

៤-ឧត្តមសេនីយ៍ឯក **សំ ចន្ទ្រផន** អត្តលេខ ០០០២០៥

៥-ឧត្តមសេនីយ៍ឯក **មាស សាមិន** អត្តលេខ ០០០០៧៩

៦-ឧត្តមសេនីយ៍ឯក **ទេវ តិរុណា** អត្តលេខ ០០០០៧៥

៧-ឧត្តមសេនីយ៍ឯក **ជា តារា** អត្តលេខ ០០០១៨៣

៨-ឧត្តមសេនីយ៍ឯក **ខ្វាន់ ស៊ាន** អត្តលេខ ០០០១០៨

៩-ឧត្តមសេនីយ៍ឯក **ជា សារិន** អត្តលេខ ០០០០៩០

១០-ឧត្តមសេនីយ៍ឯក **ស៊ុខ សំណាង** អត្តលេខ ០០០១០១

.../...

១១-ឧត្តមនារីឯក អ៊ុំ សំខាន់ អត្តលេខ ០០០០៤២

១២-ឧត្តមសេនីយ៍ឯក សៅ សុខា អត្តលេខ ០០០១០៥

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឧត្តមសេនីយ៍ទោ កែវ សាមួន អត្តលេខ ០០០១២៩

២-ឧត្តមសេនីយ៍ទោ ជា ម៉ន អត្តលេខ ០០០១៣៥

៣-ឧត្តមសេនីយ៍ទោ ម៉ុន សេខ អត្តលេខ ០០០១៤៥

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/ល.០៧០១.០២៣

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ (អប្សរា)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ (អប្សរា)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .-

ត្រូវបានកែសំរួលមាត្រា២ ជំពូកទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ដោយលុបត្រង់វាក្យខណ្ឌ :

"ស្នងការពិសេសការពារបេតិកភ័ណ្ឌនៃក្រសួងមហាផ្ទៃ អនុវត្តភារកិច្ចរបស់ខ្លួនក្នុងតំបន់អង្គរ ដោយសហការជាមួយអាជ្ញាធរខេត្តសៀមរាប" ។

មាត្រា២ថ្មី .-

អាជ្ញាធរ " អប្សរា " មានបេសកកម្មគិតគូរ ដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ នៃតំបន់ចំនួនប្រាំ ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការកំណត់ និងការចាត់ចែងតំបន់សៀមរាប អង្គរ ។

ដើម្បីសំរេចទិសដៅនេះ អាជ្ញាធរ " អប្សរា " ព្រមជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថានទាំងឡាយ ដែលមានភារកិច្ចទទួលខុសត្រូវ ក្នុងការគ្រប់គ្រងរមណីយដ្ឋានទាំងនោះសរុបមាន :

- អភិរក្សដ្ឋានអង្គរ ដែលមានបេសកកម្មថែរក្សា រៀបចំ និងជួសជុលរមណីយដ្ឋានអង្គរដោយធ្វើសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

- ភ្នាក់ងាររៀបចំការអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដែលទទួលបន្ទុកអភិវឌ្ឍន៍ និងសំរបសំរួលបណ្តាញទេសចរណ៍ក្នុងតំបន់នេះ ដោយធ្វើសហការជាមួយក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងជាមួយអនុគណៈកម្មាធិការខេត្ត រៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ។

- ភ្នាក់ងារអភិវឌ្ឍន៍នគរូបនីយកម្មទទួលបន្ទុកគិតគូរ និងធ្វើអោយបានសំរេចនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងឧបរិរចនាសម្ព័ន្ធផ្នែកទេសចរណ៍ក្នុងតំបន់នេះ ក្រោមការក្តាប់ក្តាប់ផ្ទាល់របស់អាជ្ញាធរ "អប្សរា" សហការជាមួយអភិបាលខេត្តសៀមរាប និងអនុគណៈកម្មាធិការខេត្តរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ។

- វិទ្យាស្ថានវប្បធម៌ខ្មែរដែលទទួលបន្ទុកបណ្តុះបណ្តាលប្រវត្តិវិទូ បុរាណវត្ថុវិទូ និងភ្នាក់ងារអភិរក្សទទួលបន្ទុកគ្រប់គ្រង និងទ្រទ្រង់រមណីយដ្ឋានអង្គរ ហើយនិងរ៉ាប់រងបង្កើនចំណេះដឹងទាំងឡាយនៅក្នុងផ្នែកវប្បធម៌ និងអរិយធម៌ខ្មែរដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

បណ្តាគ្រឹះស្ថានខាងលើនេះ នឹងត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

មាត្រា២ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០១០៧.០១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្គមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោកស្រី **ឈាង គឹមស៊ុន**

ជា

ឧកញ៉ា

៣រល.០៧០១.០១៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មករា ឆ្នាំ ២០០៧

លេខ: ៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

4/2,

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តមវេជ្ជបណ្ឌិត ឡុក ចយ ជាទីប្រឹក្សា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០១.០១៥

លេខ : ៤៦. ច.ល
ដើម្បីចម្លងចែក
ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ [illegible]

ស៊ុន ចិនកេន

នស/រកត/០១០៧/០១៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ខុន្សី ពៅ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ស.០៧០១.០១៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧

លេខ: ៤២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងជូនឯកឧត្តមឧត្តមសេនីយ៍ឯក ប៊ូ សីដា អត្តលេខ ០០៦៩ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពល.០៧០១.០២០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៧

លេខ : ៤៣ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០១០៧/០២០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្មមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ប៊ុច សុខិន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.០៧០១.០២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧

លេខ: 44 ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ត្រាស់ព្រះរាជទាន

ចំពោះ

លោកជំទាវ សាវ៉ាង ចំន្ទបូរ៉ា

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០១.០២២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧

លេខ: ៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើត ក្រសួងផែនការ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីកាតព្វកិច្ចធ្វើស្ថិតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៦

ស ម្រេ ច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ មានគោលដៅគ្រប់គ្រងរាល់ការងាររៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ កាតព្វកិច្ចស្ថិតិ និងការងារទាំងឡាយដែលពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២.-

វាក្យស័ព្ទសំខាន់ទាំងឡាយក្នុងអនុក្រឹត្យនេះ មានន័យដូចខាងក្រោម៖

- ស្ថិតិផ្លូវការដែលបានចាត់តាំង សំដៅដល់ស្ថិតិដែលបានផលិតដោយក្រសួង ស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ ក្នុងការរៀបចំវាយតម្លៃ គោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មាន របស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវ ក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។
- មន្ត្រីស្ថិតិដែលបានចាត់តាំង សំដៅដល់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានប្រគល់សិទ្ធិសម្រាប់អនុវត្តសកម្មភាពស្ថិតិ តាមគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។
- អង្គភាពស្ថិតិដែលបានចាត់តាំង សំដៅដល់អង្គភាពស្ថិតិកណ្តាលនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលបានកំណត់ ដោយរាជរដ្ឋាភិបាល ឱ្យទទួលខុសត្រូវក្នុងការផលិតស្ថិតិផ្លូវការ ដែលបានចាត់តាំង ស្របតាម មាត្រា ១១ និង ១២ នៃច្បាប់ស្តីពីស្ថិតិ ។
- អគ្គនាយក សំដៅដល់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ។
- ទម្រង់ ឬកម្រងសំណួរ សំដៅដល់ឧបករណ៍មួយសម្រាប់ប្រមូលទិន្នន័យ ដែលរៀបចំដោយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត ។
- ប្រព័ន្ធស្ថិតិជាតិ សំដៅដល់សមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និង

អង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

-មន្ត្រី សំដៅដល់មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ឬជាមន្ត្រីស្ថិតិដែលបានចាត់តាំង ដោយអនុលោមទៅតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ដើម្បីជួយក្នុងការអនុវត្តនូវមុខងារ របស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិរាជរដ្ឋាភិបាលដទៃទៀត ។

-ទីបរិវេណ សំដៅដល់ទីកន្លែង ដែលមិនមែនជាលំនៅដ្ឋាន ឬជាផ្នែកមួយនៃទីណាមួយក្នុងបរិវេណដែលត្រូវបានកាន់កាប់ដោយឡែក ឬប្រើប្រាស់សម្រាប់គោលបំណងនៃការរស់នៅ ឬស្នាក់នៅរបស់មនុស្ស ។

-គោលបំណងស្ថិតិ សំដៅដល់គោលបំណងដែលទាក់ទងទៅនឹងការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព ការបញ្ចូលព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច និងការផ្សព្វផ្សាយស្ថិតិផ្លូវការ ។

-កាតព្វកិច្ចស្ថិតិ សំដៅដល់ភារកិច្ច ដែលអ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មាន ស្មោះត្រង់ ត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា តាមគ្រប់សំណួរនៃការ ប្រមូល ទិន្នន័យ យោងតាមមាត្រា ១១ និង ១២ នៃច្បាប់ស្តីពីស្ថិតិ ។

ជំពូកទី២
ការរៀបចំ និងកិច្ចដំណើរការស្ថិតិ

មាត្រា៣.-

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់ ។

វិទ្យាស្ថានជាតិស្ថិតិ មាននាយកដ្ឋានមួយចំនួន សម្រាប់ទទួលខុសត្រូវលើសកម្មភាពស្ថិតិជំនាញ និងការគាំទ្រសកម្មភាពទាំងនោះ ។

វិទ្យាស្ថានជាតិស្ថិតិ មានអង្គភាពស្ថិតិនៅខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់ ។

មាត្រា៤.-

ប្រព័ន្ធស្ថិតិជាតិ ត្រូវបានបង្កើតឡើងជាប្រព័ន្ធស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

ប្រព័ន្ធស្ថិតិជាតិ មានវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត និងមន្ត្រីដែលបម្រើការងារនៅតាមអង្គភាពស្ថិតិទាំងនោះ ។

អង្គភាពស្ថិតិនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការជាក់ស្តែង ។

មាត្រា៥.-

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវដូចតទៅ៖

ក.ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

ខ.ស្រាវជ្រាវ ចងក្រងវិធីសាស្ត្រផ្សេងៗ អភិវឌ្ឍម៉ូដែល និងបច្ចេកទេសស្ថិតិ ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ ។

គ.ធានាការសម្របសម្រួល ប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព ផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់ភារកិច្ចគ្នា ក្នុងការប្រមូលព័ត៌មានសម្រាប់គោលបំណងស្ថិតិផ្លូវការដោយ អង្គភាពស្ថិតិដែលបានចាត់តាំង
- ទទួលបាននូវភាពត្រូវគ្នា និងរួមបញ្ចូលគ្នារវាងស្ថិតិផ្លូវការទាំងឡាយ ដែលចងក្រងដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ធ្វើឱ្យមានប្រសិទ្ធភាពដល់កិច្ចអភិវឌ្ឍន៍ ការរៀបចំជាឯកសារ និងការផ្សព្វផ្សាយ អំពីទស្សនៈ ប្រភព និងវិធីសាស្ត្រស្ថិតិ
- អនុវត្តគោលនយោបាយស្ថិតិ ដែលមានរួមបញ្ចូលនូវគោលនយោបាយទាក់ទងនឹង ការផ្សព្វផ្សាយស្ថិតិផ្លូវការ និងប្រតិទិនប្រកាសផ្សាយជាមុន នូវការផ្សព្វផ្សាយស្ថិតិផ្លូវការ
- បង្កើនលទ្ធភាពប្រើប្រាស់ជាអតិបរមានូវព័ត៌មាន និងមធ្យោបាយនៃការប្រមូល និងផ្សព្វផ្សាយព័ត៌មាន ដែលមាននៅតាមអង្គភាពស្ថិតិដែលបានចាត់តាំង ។

ឃ.រៀបចំគោលនយោបាយ និងបទដ្ឋានស្ថិតិសម្រាប់ការអនុវត្តឯកភាពគ្នា របស់អង្គភាពស្ថិតិដែលបានចាត់តាំង ។

ង.ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំង ទាក់ទងនឹងស្ថិតិផ្លូវការ ។

ច.ទំនាក់ទំនងជាមួយបណ្តាប្រទេសនានា និងអង្គការអន្តរជាតិនានា ដែលទាក់ទងនឹងការងារស្ថិតិ ។

វិទ្យាស្ថានជាតិស្ថិតិ ត្រូវសហការជាមួយអង្គភាពស្ថិតិផ្លូវការ ដែលបានចាត់តាំងរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិ រួមទាំងស្ថិតិដែលទទួលបានពីកំណត់ត្រារដ្ឋបាល ក្នុងគោលបំណងសម្របសម្រួលសកម្មភាពស្ថិតិ និងធានាការប្រតិបត្តិបទដ្ឋានស្ថិតិ ។

មាត្រា៦.-

អង្គភាពស្ថិតិដែលបានចាត់តាំង ជាអង្គភាពស្ថិតិកណ្តាលរបស់ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវ ដូចតទៅ៖

ក.ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

ខ.បញ្ជូនស្ថិតិដែលបានផលិត និងផ្តល់ឯកសារ វិធីសាស្ត្រដែលទាក់ទងដល់វិទ្យាស្ថានជាតិស្ថិតិ ជាទម្រង់អេឡិចត្រូនិច និងឯកសារជាក្រដាស ។

គ.សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគបោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ដើម្បី៖

- ចៀសវាងនូវការជាន់គ្នា ក្នុងសកម្មភាពស្ថិតិ និងស្ថិតិផ្លូវការ
- បន្ថយមកត្រឹមកម្រិតអប្បបរមានូវបន្ទុកអ្នកឆ្លើយ
- ទទួលបាននូវការឯកភាពគ្នា និងការរួមបញ្ចូលគ្នា រវាងស្ថិតិផ្លូវការទាំងឡាយ
- អនុវត្តគោលនយោបាយ និងបទដ្ឋានស្ថិតិ ដែលប្រកាសឱ្យប្រើដោយវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា៧.-

អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ អគ្គនាយកត្រូវបំពេញតួនាទី ភារកិច្ច តាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ហើយមិនត្រូវបំពេញការងារផ្សេងលើកលែងតែមាន ការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងផែនការ ។

អគ្គនាយកត្រូវដឹកនាំវិទ្យាស្ថានជាតិស្ថិតិ និងប្រពន្ធ័ស្ថិតិជាតិ ។

អគ្គនាយកត្រូវដឹកនាំ ត្រួតពិនិត្យការរៀបចំ និងកិច្ចដំណើរការរបស់ វិទ្យាស្ថានជាតិស្ថិតិ

ប្រព័ន្ធស្ថិតិជាតិ ហើយនិងមានមុខងារ សិទ្ធិអំណាច និងភារកិច្ចដទៃទៀត៖

ក. ផ្តល់យោបល់ អំពីការងារស្ថិតិ ។

ខ. សម្រេចអំពីរបៀបប្រមូល កែច្នៃ ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យទាំងឡាយសម្រាប់គោលដៅស្ថិតិ ។

គ. ផ្តល់ព័ត៌មានទាក់ទងនឹងបទប្បញ្ញត្តិ គោលនយោបាយស្ថិតិ ស្ថិតិផ្លូវការ និងការងារស្ថិតិដទៃទៀត ។

ឃ.តំណាងឱ្យប្រព័ន្ធស្ថិតិជាតិ ក្នុងវេទិកាអន្តរជាតិដែលទាក់ទងទៅនឹងការងារស្ថិតិ ។

មាត្រា៨.-

អគ្គនាយកត្រូវចាត់តាំងមន្ត្រី ជាលាយលក្ខណ៍អក្សរទៅតាមប្រភេទ និងកម្រិតការងារ ដើម្បីឱ្យទៅជាមន្ត្រីស្ថិតិដែលបានចាត់តាំង សម្រាប់តែគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

ប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវពិគ្រោះយោបល់ជាមួយអគ្គនាយក មុននឹងដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាត់តាំងមន្ត្រី ជាលាយលក្ខណ៍អក្សរទៅតាមប្រភេទ និងកម្រិតការងារ ឱ្យទៅជាមន្ត្រីស្ថិតិដែលបានចាត់តាំង សម្រាប់តែគោលបំណងនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

មាត្រា៩.-

អគ្គនាយកអាចចុះហត្ថលេខាធ្វើប្រតិភូកម្មដល់មន្ត្រីណាម្នាក់ នូវសិទ្ធិអំណាច សម្រាប់ចុះបំពេញការងារប្រមូលទិន្នន័យ ឬសម្របសម្រួលដើម្បីប្រមូលទិន្នន័យ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ។

សិទ្ធិអំណាចរបស់មន្ត្រី ដែលត្រូវបានទទួលប្រតិភូកម្មនៅពេលអនុវត្ត តាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ នេះត្រូវបានចាត់ទុកថាអនុវត្តដោយអគ្គនាយក ។

មាត្រា១០.-

អគ្គនាយកត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលទាក់ទងនឹងសកម្មភាព នៃកិច្ចប្រតិបត្តិការស្ថិតិ ហើយនិងការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិផ្លូវការ របស់ប្រព័ន្ធស្ថិតិជាតិសម្រាប់ឆ្នាំកន្លងមក ហើយផ្ញើជូនរដ្ឋមន្ត្រីក្រសួងផែនការ ។

រដ្ឋមន្ត្រី ក្រសួងផែនការ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនគណៈរដ្ឋមន្ត្រី ។

មាត្រា១១.-

មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ រួមមានបុគ្គលិកអចិន្ត្រៃយ៍ ដែលជាមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ ហើយបំពេញមុខងារ ដូចមានចែងក្នុងមាត្រា ១១ និង ១៩ នៃច្បាប់ស្តីពីស្ថិតិ ។

អគ្គនាយក អាចប្រើប្រាស់បុគ្គលិកបន្ថែមដែលមិនមែនជាបុគ្គលិកអចិន្ត្រៃយ៍ នៅពេល៖

ក. ធ្វើជំរឿន និងអង្កេត ។

ខ. ប្រមូលស្ថិតិផ្សេងៗ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

គ. ផ្តល់នូវប្រឹក្សាបច្ចេកទេស និងការគាំទ្រ ។

កិច្ចសន្យាអំពីរយៈពេល និងល័ក្ខខ័ណ្ឌនៃការងារ របស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ ត្រូវកំណត់ដោយអគ្គនាយក ។

មាត្រា១២.-

មន្ត្រីរបស់អង្គភាពស្ថិតិដែលបានចាត់តាំងមាន បុគ្គលិកអចិន្ត្រៃយ៍ ដែលជាមន្ត្រីរបស់អង្គភាពនោះ ហើយបំពេញមុខងារ ដែលមានចែងក្នុងមាត្រា ១២ និង ១៩ (ក) នៃច្បាប់ស្តីពីស្ថិតិ ។

អង្គភាពស្ថិតិដែលបានចាត់តាំង អាចប្រើប្រាស់បុគ្គលិកបន្ថែមដែលមិនមែនជាបុគ្គលិកអចិន្ត្រៃយ៍ ដោយពិគ្រោះយោបល់ជាមួយ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៅពេល៖

ក. ធ្វើអង្កេត ។

ខ. ប្រមូលស្ថិតិផ្សេងៗ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ ។

គ. ផ្តល់នូវប្រឹក្សាបច្ចេកទេស និងការគាំទ្រ ។

កិច្ចសន្យា អំពីរយៈពេល និងល័ក្ខខ័ណ្ឌនៃការងារ របស់បុគ្គលិកមិនមែនអចិន្ត្រៃយ៍ ត្រូវកំណត់ដោយក្រសួង ឬស្ថាប័ន ដោយពិគ្រោះយោបល់ជាមួយអគ្គនាយក ។

ជំពូកទី៣
ក្រុមប្រឹក្សាស្ថិតិ

មាត្រា១៣.-

ក្រុមប្រឹក្សាស្ថិតិ ដែលបានបង្កើតដោយអនុលោមតាមមាត្រា ១៥ នៃច្បាប់ស្តីពីស្ថិតិ មាន

សមាសភាព ដូចតទៅ៖

រដ្ឋមន្ត្រី ក្រសួងផែនការ	ជាប្រធាន
រដ្ឋលេខាធិការ ក្រសួងផែនការ ទទួលបន្ទុកស្ថិតិ	ជាអនុប្រធាន
រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង ពាណិជ្ជកម្ម	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង អប់រំ យុវជន និងកីឡា	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង សុខាភិបាល	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង សាធារណការ និងដឹកជញ្ជូន	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង ទេសចរណ៍	ជាសមាជិក
រដ្ឋលេខាធិការ ក្រសួង កិច្ចការនារី	ជាសមាជិក
ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា	ជាសមាជិក
តំណាង មជ្ឈដ្ឋានឧត្តមសិក្សាមួយនាក់ដែល ជ្រើសរើសដោយរដ្ឋមន្ត្រី ក្រសួងផែនការ	ជាសមាជិក
អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ	ជាសមាជិកអចិន្ត្រៃយ៍ ។

ប្រធានក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍អាជីវកម្ម ចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់ ។

មាត្រា១៤.-

ក្រុមប្រឹក្សាស្ថិតិ ត្រូវប្រជុំការងារ យ៉ាងតិចពីរដង ក្នុងមួយឆ្នាំ។ សមាជិកក្រុមប្រឹក្សាស្ថិតិ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្តាល នៃសមាជិកទាំងអស់សម្រាប់បើកអង្គប្រជុំ ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ត្រូវមានសមាជិកចូលរួមយ៉ាងតិចមួយភាគបី នៃសមាជិកទាំងអស់ ។

សេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សាស្ថិតិ ត្រូវអនុម័តដោយយកមតិភាគច្រើន របស់សមាជិកចូលរួមទាំងអស់ ។

រដ្ឋមន្ត្រីក្រសួងផែនការ ដែលជាប្រធានក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិអនុម័តសម្រេច ក្នុងករណីដែលមានមតិស្មើគ្នា ។

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវមានកំណត់ហេតុ ។

មាត្រា១៥.-

ក្រុមប្រឹក្សាស្ថិតិ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងផែនការ ។ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការត្រូវផ្តល់លេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្ថិតិ ។

មាត្រា១៦.-

ក្រុមប្រឹក្សាស្ថិតិ មានតួនាទីផ្តល់យោបល់ជូន រដ្ឋមន្ត្រី ក្រសួងផែនការ ដែលទាក់ទងទៅនឹង៖

-ការកំណត់គោលនយោបាយស្ថិតិផ្លូវការ

-តម្រូវការស្ថិតិផ្លូវការ និងការផ្តល់អាទិភាពដល់គម្រោងការងារស្ថិតិ ដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង

-ការធ្វើឱ្យប្រសើរឡើង ការពង្រីក និងការសម្របសម្រួលនូវប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលបានចាត់តាំង សម្រាប់គោលបំណងសាធារណៈ

-ការធ្វើវិសោធនកម្មណាមួយទៅលើច្បាប់ស្តីពីស្ថិតិ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធការងារស្ថិតិ

-កម្មវិធីការងារស្ថិតិអាទិភាពរយៈពេល ១ ឆ្នាំ រយៈពេលមធ្យម រយៈពេលវែង របស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដែលទាក់ទងក្នុងការផលិតស្ថិតិផ្លូវការ

-ផែនការមេស្ថិតិ

-ការកំណត់កាលបរិច្ឆេទ នៃការធ្វើជំរឿនប្រជារាស្ត្រ កសិកម្ម និងសហគ្រាស

-ការងារផ្សេងៗ ដែលទាក់ទងជាទូទៅនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

-ការស្វែងរកជំនួយ និងការគាំទ្រ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលត្រូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីធ្វើជំរឿន អង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលបំណងសាធារណៈ ។

ជំពូកទី៤
គណៈកម្មាធិការសម្របសម្រួលស្ថិតិ

មាត្រា១៧.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ដោយអនុលោមតាមមាត្រា ១៦ នៃច្បាប់ស្តីពីស្ថិតិ មានសមាសភាព ដូចខាងក្រោម ៖

អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ	ជាប្រធាន
អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ	ជាអនុប្រធាន
ប្រធាន នាយកដ្ឋានស្ថិតិទូទៅ នៃវិទ្យាស្ថានជាតិស្ថិតិ	ជាលេខាធិការ
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង មហាផ្ទៃ	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការពារជាតិ	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង អភិវឌ្ឍន៍ជនបទ	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ពាណិជ្ជកម្ម	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង បរិស្ថាន	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង អប់រំ យុវជន និងកីឡា	ជាសមាជិក
ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួងធម្មការ និងសាសនា	ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ធនធានទឹក និងឧតុនិយម ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ព័ត៌មាន ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង យុត្តិធម៌ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង សុខាភិបាល ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ទេសចរណ៍ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង កិច្ចការនារី ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ធនាគារជាតិ នៃកម្ពុជា ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ ទីចាត់ការគយ និងរដ្ឋាករ ជាសមាជិក

ប្រធាន ឬអនុប្រធានអង្គភាពស្ថិតិ នាយកដ្ឋានពន្ធដារ ជាសមាជិក ។

មាត្រា១៨.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវប្រជុំការងារយ៉ាងតិចរាល់ ៣ ខែម្តង ។ សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្ដាល នៃសមាជិកទាំងអស់ សម្រាប់បើកអង្គប្រជុំ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ មិនគិតចំនួនសមាជិកចូលរួមឡើយ។

សេចក្ដីសម្រេចរបស់ អង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវអនុម័តដោយយកមតិភាគច្រើនរបស់សមាជិកចូលរួមទាំងអស់ ។

អគ្គនាយក ដែលជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិអនុម័តសម្រេចក្នុងករណីដែលមានមតិស្មើគ្នា ។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវមានកំណត់ហេតុ ។

មាត្រា១៩.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិប្រើប្រាស់ត្រាវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ។

នាយកដ្ឋានស្ថិតិទូទៅ នៃវិទ្យាស្ថានជាតិស្ថិតិ ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ។

មាត្រា២០.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការងារពាក់ព័ន្ធទៅនឹង៖

-ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និង ស្ថិតិផ្លូវការ

-ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពលើសកម្មភាព និងការអភិវឌ្ឍស្ថិតិ រវាងអង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវ ក្នុងការផលិតនិងការផ្សព្វផ្សាយស្ថិតិផ្លូវការ

-ការធ្វើឱ្យប្រសើរឡើង និងការពង្រីកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលផ្ដល់សម្រាប់គោលដៅសាធារណៈ

-ការលើកអាទិភាព នៃកម្មវិធីការងារ ប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែងដែលគួរ

ត្រូវបានជ្រើសរើស ទាក់ទងនឹងទិដ្ឋភាពសំខាន់ៗ នៃការផ្តល់ស្ថិតិផ្លូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង

-ការរៀបចំ និងធ្វើបច្ចុប្បន្នកម្ម ផែនការមេស្ថិតិ

-ការរៀបចំផែនការ ធ្វើជំរឿនប្រជារាស្ត្រ កសិកម្ម និងសហគ្រាស

-ការបង្កើតនូវបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសរុប បញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាព និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ

-កិច្ចព្រមព្រៀងសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល រវាងបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរទិន្នន័យ និងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឱ្យបានទៀងទាត់ និងគួរជឿទុកចិត្តបាន

-ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ សម្រាប់ស្ថិតិណាមួយ ឬការងារស្ថិតិផ្សេងទៀត ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

-ការប្រកាសឱ្យប្រើ និងការអនុវត្តនូវចំណាត់ថ្នាក់ និងបទដ្ឋានស្ថិតិ ដែលទាក់ទងនឹងស្ថិតិផ្លូវការ

-ការលើកផែនការថវិកា និងធនធានមនុស្ស សម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និងអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលដៅសាធារណៈ ។

មាត្រា២១.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ ដើម្បីដោះស្រាយការងារបច្ចេកទេសស្ថិតិណាមួយ ដែលទាមទារការពិនិត្យ សិក្សា និងពិភាក្សាលម្អិត ។

គណៈកម្មាធិការសម្របសម្រួលស្ថិតិ នឹងកំណត់ល័ក្ខខ័ណ្ឌយោង ដែលមានចែងពីភារកិច្ច និងបែបបទធ្វើរបាយការណ៍ ស្តីពីលទ្ធផលរបស់ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗ ។

ក្រុមការងារបច្ចេកទេសស្ថិតិនីមួយៗ ត្រូវរៀបចំសមាសភាពដូចខាងក្រោម៖

- សមាជិក ១ រូប របស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ប្រធាន
- ប្រធាន ឬអនុប្រធាននាយកដ្ឋាន ១ រូប នៃវិទ្យាស្ថានជាតិស្ថិតិ អនុប្រធាន
- សមាជិកដទៃទៀតមកពីបណ្តាក្រសួង ស្ថាប័ន ឬអង្គភាព

រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ រួមទាំងវិទ្យាស្ថានជាតិស្ថិតិ
ដែលមានចំនួនមិនលើសពី ៥ រូបទៅតាមការកំណត់របស់
គណៈកម្មាធិការសម្របសម្រួលស្ថិតិ សមាជិក ។

ជំពូកទី៥
សិទ្ធិ និងភារកិច្ច

មាត្រា២២.-

វិទ្យាស្ថានជាតិស្ថិតិ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងការងារស្ថិតិត្រូវប្រមូល៖

-ព័ត៌មានស្ថិតិជាចាំបាច់សម្រាប់គោលបំណង នៃការចងក្រង និងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង

-ព័ត៌មានស្ថិតិបន្ថែម ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលសម្រាប់គោលដៅធ្វើផែនការ និងគោលនយោបាយ

-ព័ត៌មានស្ថិតិពាក់ព័ន្ធទៅនឹងបញ្ហា ដែលបានកំណត់ជាលាយលក្ខណ៍អក្សរ ដោយរដ្ឋមន្ត្រីក្រសួងផែនការ ឱ្យប្រមូលព័ត៌មាន ។

អង្គភាពស្ថិតិដែលបានចាត់តាំង ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះត្រូវប្រមូលព័ត៌មានស្ថិតិជាចាំបាច់ សម្រាប់គោលបំណងនៃការចងក្រង និងការវិភាគស្ថិតិផ្លូវការដែលបានចាត់តាំង ដែលអង្គភាពស្ថិតិនោះទទួលខុសត្រូវ ។

មាត្រា២៣.-

អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវចងក្រង និងវិភាគព័ត៌មានស្ថិតិដែលបានប្រមូល ក្រោមសិទ្ធិអំណាចនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនេះ ហើយត្រូវបោះពុម្ព និងផ្សព្វផ្សាយនូវលទ្ធផលដែលបានចងក្រង និងវិភាគ ឬសម្រង់សង្ខេប នៃលទ្ធផលទាំងនោះ ។ លទ្ធផល ឬសម្រង់សង្ខេបនោះ នឹងមិនត្រូវបានបោះពុម្ព ឬផ្សព្វផ្សាយតាមរបៀប ដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពណាមួយឡើយ ។

មាត្រា២៤.-

មន្ត្រីស្ថិតិទាំងឡាយ ដែលត្រូវបានប្រគល់សិទ្ធិ ឱ្យចុះប្រតិបត្តិការការងារស្ថិតិ យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យពាក់ព័ន្ធ ត្រូវចុះកិច្ចសន្យាដោយមានសាក្សីទទួលដឹងឮ ដើម្បីធានា៖

- ភាពស្មោះត្រង់
- រក្សាការសម្ងាត់ នូវរាល់ព័ត៌មានបុគ្គលដែលទទួលបានពីអ្នកឆ្លើយ
- ព័ត៌មានដែលប្រមូលបានត្រូវប្រើប្រាស់សម្រាប់តែគោលដៅស្ថិតិប៉ុណ្ណោះ ។

មាត្រា២៥.-

ក្នុងករណីពិសេស រដ្ឋមន្ត្រីក្រសួងផែនការអាចសម្រេចជាលាយលក្ខណ៍អក្សរ ផ្តល់ឱ្យនូវកម្រិតព័ត៌មានបុគ្គលណាមួយ តាមការស្នើសុំពីអគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ជាលាយលក្ខណ៍អក្សរ ។

ការសម្រេចផ្តល់ឱ្យអាចពាក់ព័ន្ធទៅនឹង៖

ក. បុគ្គលដែលស្នើសុំព័ត៌មាន។

ខ. តម្រូវការយល់ព្រមពីអ្នកឆ្លើយដែលបានផ្តល់ព័ត៌មាន។

គ. ការបញ្ជាក់រយៈពេល និងល័ក្ខខ័ណ្ឌប្រើប្រាស់ព័ត៌មានដែលបានផ្តល់ឱ្យ ដូចជាមិនបញ្ចេញព័ត៌មានដល់បុគ្គលណាមួយទៀតឡើយ ។

ព័ត៌មានដែលមានចរិតបុគ្គល ឬផ្ទាល់ខ្លួនទាក់ទងនឹងអ្នកឆ្លើយ មិនត្រូវបានបញ្ចេញដោយរបៀបដែលអាចឱ្យសម្គាល់អត្តសញ្ញាណរបស់បុគ្គលនោះ ។

ព័ត៌មានអំពីលេខ នៃការចុះបញ្ជីអាជីវកម្ម ឈ្មោះ អាសយដ្ឋាន ទីតាំង ប្រភេទ នៃការចាត់តាំងផ្លូវច្បាប់ ផ្នែកផលិតកម្ម ចំនួនអ្នកធ្វើការ ឬកម្រិតថ្នាក់អថេរដទៃទៀត នៃអង្គភាពកសិកម្ម និងសហគ្រាស ហើយនិងអង្គភាពផ្សេងទៀត ដែលជាតម្រូវការរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីបង្កើតក្របខ័ណ្ឌជំរឿន និងអង្កេត សម្រាប់គោលបំណងនៃការដឹកនាំសកម្មភាពប្រមូលទិន្នន័យ និងចងក្រងស្ថិតិផ្លូវការថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន មិនតម្រូវឱ្យមានការយល់ព្រមពីអ្នកឆ្លើយឡើយ ។

មាត្រា២៦.-

មន្ត្រីស្ថិតិ នៃក្រសួងផែនការ ឬមន្ត្រីស្ថិតិដែលបានចាត់តាំង យោងតាមមាត្រា ២៣ និងមាត្រា ២៤ នៃច្បាប់ស្តីពីស្ថិតិ ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន អត្តសញ្ញាណប័ណ្ណផ្លូវការ និងដោយមាន

ការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬអ្នកស្នាក់នៅ អាចចូលក្នុងលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅរួមមាន ផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅដោយឡែក និងទីកន្លែងផ្សេងៗទៀត តាមវេលាដ៏សមស្រប សម្រាប់គោលបំណង៖

ក. ផ្តល់កម្រងសំណួរ ឬទម្រង់ស្ថិតិ ឱ្យបុគ្គលបំពេញ ។

ខ. ប្រមូលកម្រងសំណួរ ឬទម្រង់ស្ថិតិ ដែលបុគ្គលបានបំពេញហើយ ។

គ. ធ្វើការសម្ភាសន៍ និងបំពេញការងារផ្សេងៗទៀត សម្រាប់គោលបំណងស្ថិតិ ។

មាត្រា២៧.-

ក.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

-រៀបចំកម្រងសំណួរ ឬទម្រង់ស្ថិតិទាក់ទងនឹងការប្រមូលព័ត៌មានស្ថិតិពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ

-អាចធ្វើលិខិតតម្រូវឱ្យបុគ្គលដែលមានជំនាញ និងការទទួលខុសត្រូវជាក់លាក់ ដើម្បីបំពេញកម្រងសំណួរ ឬទម្រង់ស្ថិតិ តាមការណែនាំសម្រាប់បំពេញ ។

ខ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាច៖

- ឱ្យបុគ្គលបំពេញ និងផ្តល់ព័ត៌មានស្ថិតិ តាមការណែនាំជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់

-មានវិធានការចាំបាច់ ដើម្បីជំរុញឱ្យបុគ្គលបំពេញកម្រងសំណួរ ឬទម្រង់ស្ថិតិឱ្យបានត្រឹមត្រូវសព្វគ្រប់ តាមការណែនាំ ។

គ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង អាចចេញលិខិតជូនដំណឹងដោយភ្ជាប់ជាមួយនឹងកម្រងសំណួរ ឬទម្រង់ស្ថិតិផ្ញើទៅបុគ្គលតាមរយៈប្រៃសណីយ៍ ឬមន្ត្រីស្ថិតិជាតំណាងជូនដល់ផ្ទាល់ដៃ ។ បុគ្គលដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ត្រូវបំពេញដោយទទួលខុសត្រូវ នូវចម្លើយឱ្យបានសព្វគ្រប់តាមការណែនាំ ហើយផ្ញើកម្រងសំណួរ ឬទម្រង់ស្ថិតិដែលបានបំពេញហើយនោះ មកអគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងរយៈពេលមិនឱ្យលើសពី ១៤ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ។

ឃ. លិខិតជូនដំណឹងរបស់អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិ ដែលមានចែងក្នុងមាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់ស្តីពីស្ថិតិ ។

មាត្រា២៨.-

ក.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ឬមន្ត្រីស្ថិតិដែលបានចាត់តាំងអាចឱ្យបុគ្គលឆ្លើយ នូវសំណួរណាមួយដែលចាំបាច់ ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

ខ.អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំង ដោយលិខិតជាលាយលក្ខណ៍អក្សរ ឬដោយខ្លួនផ្ទាល់ ឬដោយចាត់មន្ត្រីស្ថិតិជាតំណាង អាចណែនាំឱ្យបុគ្គលផ្តល់ចម្លើយនូវសំណួរណាមួយដែលចាំបាច់ក្នុងរយៈពេលមិនឱ្យលើសពី ១៤ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលសំណួរ ។

គ.សំណួររបស់អគ្គនាយក ឬប្រធានអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជាក់អំពីទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៨ និងមាត្រា២៩ នៃច្បាប់ស្តីពីស្ថិតិ ។

ជំពូកទី៦

ទោសប្បញ្ញត្តិ

មាត្រា២៩.-

បុគ្គលណា ដែលរំលោភបញ្ញត្តិ នៃមាត្រា២៥ មាត្រា២៧ និងមាត្រា២៨ នៃអនុក្រឹត្យនេះត្រូវមានទោសព្រហ្មទណ្ឌ តាមច្បាប់ជាធរមាន ។

មាត្រា៣០.-

បុគ្គលដែលបានទទួលកម្រងសំណួរ ឬទម្រង់ស្ថិតិ ដែលតម្រូវឱ្យបំពេញក្នុងរយៈពេលកំណត់ដូចមានចែងក្នុង មាត្រា ២៧ ចំណុច គ ឬមាត្រា ២៨ ចំណុច ខ នៃអនុក្រឹត្យនេះ នៅតែមានកាតព្វកិច្ចបំពេញការងារនេះឱ្យបានសម្រេច ជាស្ថាពរ ។

ជំពូកទី៧

អវសានប្បញ្ញត្តិ

មាត្រា៣១.-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងប្រធានស្ថាប័ន រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១០៩

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៤បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន ០៤បន្ទប់ និង អណ្តូងទឹក ០១ ជូនអនុវិទ្យាល័យ ***ឡាយអ៊ីនគ្រីបជីបាប្រ៉ោយ*** ស្ថិតក្នុងឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី	**NAOMI ISHIGE**	ថវិកា ចំនួន	២៧.២៥០ ដុល្លារ
២-លោកស្រី	**KIKUE MISONO**	ថវិកា ចំនួន	២៧.៣៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៣០៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តរតនគិរី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រីសំខាន់ៗ ចំនួន ០៥រូប ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការកសាងអគារសិក្សា នៅអនុវិទ្យាល័យអន្លង់វាសិកដ្ឋានបានលុង ខេត្តរតនគិរី ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមរយៈគណៈកម្មាធិការប្រជាជនខេត្តយ៉ាឡាយ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម	**ឡេ ទៀនហ៊ៀង**	អនុប្រធានគណៈកម្មាធិការប្រជាជនខេត្តយ៉ាឡាយ វៀតណាម
២-លោក	**ង្វៀន ស៊ីនយ៉ាង**	នាយកគ្រប់គ្រងកិច្ចការវិនិយោគ និងសាងសង់គោលដៅគំរោង នៃ ខេត្តយ៉ាឡាយ វៀតណាម
៣-លោក	**ឡុង ទៀនយុង**	ប្រធានគ្រប់គ្រងការដ្ឋានសំណង់របស់ ខេត្តយ៉ាឡាយ /វៀតណាម
៤-លោក	**ម៉ូ ឡៅ**	អភិបាលរងខេត្តរតនគិរី ប្រធានគណៈកម្មការខេត្តសំរាប់ការងារសាងសង់ គំរោងជំនួយ
៥-លោក	**ឆាន់ ធីរុណ**	នាយកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាអនុប្រធានគណៈកម្មការខេត្ត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៧១......អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

ៜ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ ក្រសួងអប់រំ និងបណ្តុះបណ្តាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៥រូប ដែលមានគុណបំណាច់និងស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការលើវិស័យអប់រំ រវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ដូចមានរាយនាមខាងក្រោម :-

ក_មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ត្រឹន ហ៊ាន់ឡុង** អនុរដ្ឋមន្ត្រី ក្រសួង អប់រំ និង បណ្តុះបណ្តាល

ខ_មេដាយសហមេត្រី ថ្នាក់ សេនា :

១-លោកស្រី **ត្រឹន ធីហា** អគ្គនាយកឧត្តមសិក្សា និង ក្រោយឧត្តមសិក្សា

២-លោក **ត្រឹន ឆាទៀតហ៊ុង** អគ្គនាយកសហប្រតិបត្តិការអន្តរជាតិ

៣-លោកសាស្ត្រាចារ្យបណ្ឌិត **ង្វៀន ទៀតមិញ** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ អប់រំហាណូយ

៤-លោកសាស្ត្រាចារ្យបណ្ឌិត **ង្វៀន ហ៊ាន ជៀង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសេដ្ឋកិច្ចជាតិ ហាណូយ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ.....៣៤២.....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី ការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-ឧត្តមសេនីយ៍ឯក **ឈៀង សារុន** អត្តលេខ ០០០០៣៥ ជា នាយរងលេខាធិការចំរុះ និងជា នាយក ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ទោ **ជា ជាវរិទ្ធ** អត្តលេខ ០០០២៩៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៣-ឧត្តមសេនីយ៍ត្រី **ទឹម សុន** អត្តលេខ ០០០៣៦៤ ជា នាយក ទីចាត់ការឃោសនាព័ត៌មាន អគ្គបញ្ជាការដ្ឋាន

៤-ឧត្តមសេនីយ៍ត្រី **ដេង កុយ** អត្តលេខ ០០០៦៣៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឧត្តមសេនីយ៍ត្រី មាស សក្តិ អត្តលេខ ០០០៧៤៧ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៦-ឧត្តមសេនីយ៍ត្រី សេង ចាន់ធី អត្តលេខ ០០០៥៩០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៧-ឧត្តមសេនីយ៍ត្រី ឯម ចាន់ឡី អត្តលេខ ០០០៦៣០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៨-ឧត្តមសេនីយ៍ត្រី មួន សុមង្គល អត្តលេខ ០០០២៧០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៩-ឧត្តមសេនីយ៍ត្រី ជឹម សុខ អត្តលេខ ០០០៦៤៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១០-ឧត្តមសេនីយ៍ត្រី មាស ម៉ែន អត្តលេខ ០០០២៧១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១១-ឧត្តមសេនីយ៍ត្រី ជា សុមណ្ឌារុម អត្តលេខ ០០០៨៦២ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១២-ឧត្តមសេនីយ៍ត្រី អន គឹមសត់ អត្តលេខ ០០០៦៣៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-ឧត្តមសេនីយ៍ត្រី នួន ម៉ន អត្តលេខ ០០០២៩៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៤-ឧត្តមសេនីយ៍ត្រី ម៉ោម គួយ អត្តលេខ ០០៣០៨៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៥-ឧត្តមសេនីយ៍ត្រី ម៉ុន ឃួន អត្តលេខ ០០០២៧៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៦-ឧត្តមសេនីយ៍ត្រី ម៉ុខ ខុម អត្តលេខ ០០០៤៧៧ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៧-ឧត្តមសេនីយ៍ត្រី មាស សុវណ្ណ អត្តលេខ ០០០០៩៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៨-ឧត្តមសេនីយ៍ត្រី ម៉ី ចាន់នី អត្តលេខ ០០០៣១៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៩-ឧត្តមសេនីយ៍ត្រី ឃួន មុយឃួន អត្តលេខ ០០០៧១៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២០-ឧត្តមសេនីយ៍ត្រី ចាន់ ម៉ុននី អត្តលេខ ០០០១០៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២១-ឧត្តមសេនីយ៍ត្រី កែវ សឿន អត្តលេខ ០០០៣០៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២២-ឧត្តមសេនីយ៍ត្រី សុខ នារា អត្តលេខ ០០៣៨១១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៣-ឧត្តមសេនីយ៍ត្រី ម៉ែន ម៉ុនណារី អត្តលេខ ០០០៣១៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៤-ឧត្តមសេនីយ៍ត្រី គឹម សំអាន អត្តលេខ ០០០៣១៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៥-ឧត្តមសេនីយ៍ត្រី ម៉ែន ចាន់ អត្តលេខ ០០០៣២៥ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៦-ឧត្តមសេនីយ៍ត្រី នួន បូរិទ្ធ អត្តលេខ ០០០៣២៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៧-ឧត្តមសេនីយ៍ត្រី ប្រាក់ ផល្លី អត្តលេខ ០០២១០៥ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៨-ឧត្តមសេនីយ៍ត្រី អ៊ុម សុផុន អត្តលេខ ០០០៥៧៦ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២៩-ឧត្តមសេនីយ៍ត្រី សុខ ចាន់ អត្តលេខ ០០៧៣០ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៣០-ឧត្តមសេនីយ៍ត្រី ឃួន ឡឹម អត្តលេខ ០០០៧៣៤ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៣១-ឧត្តមសេនីយ៍ត្រី សួស សារិន អត្តលេខ ០០០២៨៨ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

៣២-ឧត្តមសេនីយ៍ត្រី ពេជ្រ សារ៉ន អត្តលេខ ០០០៤៩៤ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

៣៣-ឧត្តមសេនីយ៍ត្រី **សោម សាធី** អត្តលេខ ០០២២៩១ ជា សាកលវិទ្យាធិការរង
សាកលវិទ្យាល័យការពារជាតិ

៣៤-ឧត្តមសេនីយ៍ត្រី **ជាញ់ សារម៉ន** អត្តលេខ ០០៣២៨៧ ជា សាកលវិទ្យាធិការរង
សាកលវិទ្យាល័យការពារជាតិ

៣៥-ឧត្តមសេនីយ៍ត្រី **មាច់ មីនា** អត្តលេខ ០០១២០២ ជា នាយក មហាវិទ្យាល័យការពារជាតិ
សាកលវិទ្យាល័យការពារជាតិ

៣៦-ឧត្តមសេនីយ៍ត្រី **គីម ចន្ទសារ៉ុម** អត្តលេខ ០០២០៤០ ជា នាយក មហាវិទ្យាល័យបញ្ជាការសេនាធិការ
សាកលវិទ្យាល័យការពារជាតិ

៣៧-ឧត្តមសេនីយ៍ត្រី **ដោក សុផា** អត្តលេខ ០០២០២១ ជា នាយក មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម
និង ភាសា សាកលវិទ្យាល័យការពារជាតិ

៣៨-ឧត្តមសេនីយ៍ត្រី **នាង នាច** អត្តលេខ ០០១៩៨៧ ជា នាយក មហាវិទ្យាល័យព័ត៌មានវិទ្យា និង
ភស្តុភារ-ហិរញ្ញវត្ថុ សាកលវិទ្យាល័យការពារជាតិ

៣៩-ឧត្តមសេនីយ៍ត្រី **យ៉ង មោមផៅរី** អត្តលេខ ០០១៦៨៤ ជា នាយក មហាវិទ្យាល័យ អប់រំចិត្តសាស្ត្រ
វិទ្យាសាស្ត្រយោធា សាកលវិទ្យាល័យការពារជាតិ

៤០-វរសេនីយ៍ឯក **ឆាម ឌួច** អត្តលេខ ០០០៩៣៧ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៣...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ទោ	**សុខ ពិទូ**	អត្តលេខ ០២៥៧០២	ជំនួយការ ឯកឧត្តម **នាង ផាត**
២-វរសេនីយ៍ទោ	**អៀម គីមឈី**	អត្តលេខ ០១៥២៣០	ជំនួយការ ឯកឧត្តម **នាង ផាត**
៣-វរសេនីយ៍ទោ	**ម៉ៃ ស៊ីវុត្ថា**	អត្តលេខ ០០២៦០៥	ជំនួយការផ្ទាល់ ឯកឧត្តម **គៀង សាមុន**
៤-វរសេនីយ៍ទោ	**និត្យ ចំរុងចូណ៌ទី**	អត្តលេខ ០០៨៣៥៨	លេខាផ្ទាល់ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា
៥-វរសេនីយ៍ទោ	**រស់ កុសល**	អត្តលេខ ០០១៤៦៩	នាយលេខាធិការដ្ឋានទីប្រឹក្សា

៦-វរសេនីយ៍ទោ ស្វាយ ចំឆ្លងសិរីសុខា អត្តលេខ ០២៥២៦៦ ជំនួយការ ខុទ្ទកាល័យ រដ្ឋមន្ត្រី ក្រសួងការពារជាតិ

៧-វរសេនីយ៍ទោ ឡុង ហ៊ឿន អត្តលេខ ០០២០១០ ជំនួយការ ឯកឧត្តម ម៉ឺន សឿង

៨-វរសេនីយ៍ទោ អាន់ សឿន អត្តលេខ ០០១៣២២ នាយលេខាធិការដ្ឋាន នាយកដ្ឋានសរុប

៩-វរសេនីយ៍ទោ អ៊ុំ សុខី អត្តលេខ ០០១៦៣០ លេខាផ្ទាល់ ឯកឧត្តម ឆាន់ ខួន

១០-វរសេនីយ៍ទោ អ៊ូ សេដ្ឋានូ អត្តលេខ ០០៨៦២៩ លេខា ឯកឧត្តម ជុំ សម៉ឿន

១១-វរសេនីយ៍ទោ ចៅ ពលៈ អត្តលេខ ០២៤៨៤២ នាយការិយាល័យផលិតកម្ម នាយកដ្ឋានផលិតសំភារៈយោធា

១២-វរសេនីយ៍ទោ ឈឹម សុភន អត្តលេខ ០០៨៩៩១ លេខាផ្ទាល់ ឯកឧត្តម ចៅ សិរុណ

១៣-វរសេនីយ៍ទោ គង់ ណោរ៉ាន់ អត្តលេខ ០០១៥៨៩ នាយអង្គភាពរោងជាងជួសជុលចំរុះ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១៤-វរសេនីយ៍ទោ សូ សារឹម អត្តលេខ ០១៣៩៣៣ នាយការិយាល័យសំភារៈ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១៥-វរសេនីយ៍ទោ រំដួល ដំឈូរ អត្តលេខ ០០១៩៣៨ នាយការិយាល័យក្របខ័ណ្ឌ និងបំពាក់
នាយកដ្ឋានបំពាក់សំភារៈសឹក

១៦-វរសេនីយ៍ទោ ខុយ សារ៉េត អត្តលេខ ០០១៥៧៣ នាយករងមជ្ឈមណ្ឌលហ្វឹកហ្វឺន និងជួសជុល បញ្ជូនសារ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១៧-វរសេនីយ៍ទោ ស៊ុយ ចាន់ណារិទ្ធ អត្តលេខ ០០១៥៨៤ ជំនួយការផ្ទាល់ ឯកឧត្តម ចៅ សិរុណ

១៨-វរសេនីយ៍ទោ ឌួន សុធីរ អត្តលេខ ០១៣៩១៨ នាយការិយាល័យផែនការ នាយកដ្ឋានការពារគីមីសាស្ត្រ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១៩-វរសេនីយ៍ទោ កែវ សំណឺ អត្តលេខ ០០១៩៣៨ នាយការិយាល័យពិសោធន៍ នាយកដ្ឋានការពារ គីមីសាស្ត្រ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២០-វរសេនីយ៍ទោ ម៉ៅខ ស៊ីថា អត្តលេខ ០១១៣៥៤ នាយឃ្លាំងគីមីសាស្ត្រ នាយកដ្ឋានការពារគីមីសាស្ត្រ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២១-វរសេនីយ៍ទោ ឡឿង សុវណ្ណនាន អត្តលេខ ០០១៣៥៨ នាយការិយាល័យការពារគីមីសាស្ត្រ នាយកដ្ឋានការពារ
គីមីសាស្ត្រ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២២-វរសេនីយ៍ទោ មន្ទន់ ពិសិដ្ឋ អត្តលេខ ០០១៣៥៨ នាយលេខាធិការដ្ឋាន នាយកដ្ឋានការពារ គីមីសាស្ត្រ
អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២៣-វរសេនីយ៍ទោ **សេក មន្ថា** អត្តលេខ ០០៨៤១៥ នាយអង្គភាពដឹកជញ្ជូនការពារ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២៤-វរសេនីយ៍ទោ **កែវ ម៉ូនណា** អត្តលេខ ០០៥០៤៧ នាយការិយាល័យ បច្ចេកទេសឧទ្ធម្ភាគចក្រ កងពលតូចដឹកជញ្ជូនប្រតិភូជាន់ខ្ពស់

២៥-វរសេនីយ៍ទោ **អ៊ុន សុផល** អត្តលេខ ០០៥០៤២ នាយប្រតិបត្តិការហ្វឹកហ្វឺន កងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់

២៦-វរសេនីយ៍ទោ **ជា អរុណ** អត្តលេខ ០២១៧៣៧ នាយការិយាល័យអធិការកិច្ច កងទ័ពជើងទឹកអធិការដ្ឋាន អគ្គបញ្ជាការដ្ឋាន

២៧-វរសេនីយ៍ទោ **តាន់ ឫទ្ធី** អត្តលេខ ០០៤៩១៦ នាយការិយាល័យវិន័យទណ្ឌកម្ម ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

២៨-វរសេនីយ៍ទោ **សៅ គង់** អត្តលេខ ០០៨៨០២ មេបញ្ជាការរង កងពលតូចដឹកជញ្ជូនលេខ៩០ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន

២៩-វរសេនីយ៍ទោ **ខៅខ សុឃីម៉ូ** អត្តលេខ ០០៨៨៧២ នាយការិយាល័យព័ត៌មានឯកសារ ទីចាត់ការឃោសនាព័ត៌មាន អគ្គបញ្ជាការដ្ឋាន

៣០-វរសេនីយ៍ទោ **ឡុង សាខន** អត្តលេខ ០០២៤៥៦ នាយសេនាធិការរង បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការដ្ឋាន

៣១-វរសេនីយ៍ទោ **សុខ ម៉ារ៉េន** អត្តលេខ ០០២៩៧០ នាយសេនាធិការរង កងពលធំអន្តរាគមន៍លេខ២ អគ្គបញ្ជាការដ្ឋាន

៣២-វរសេនីយ៍ទោ **អ៊ុក សុផាន** អត្តលេខ ០០៤៧៣៦ នាយការិយាល័យទី ២ បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៣-វរសេនីយ៍ទោ **មួង ម៉ុន្ថា** អត្តលេខ ០០៣៤៩៧ នាយរងការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៤-វរសេនីយ៍ទោ **ឈុន សេង** អត្តលេខ ០០៣៥៩៣ នាយរងការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៥-វរសេនីយ៍ទោ **សុទ្ធ រិទ្ធី** អត្តលេខ ០០២០៥២ នាយរងការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៦-វរសេនីយ៍ទោ **អ៊ុច ចាន់នី** អត្តលេខ ០០២៧៧៣ នាយរងការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៧-វរសេនីយ៍ទោ **មាស សុខេម** អត្តលេខ ០១៤៦០៦ នាយរងការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៨-វរសេនីយ៍ទោ **ជា ស្រេង** អត្តលេខ ០០៤៨៩៨ នាយរងការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៩-វរសេនីយ៍ទោ **សេង តេជះ** អត្តលេខ ០១៦៨១៤ នាយរោងពុម្ពទីចាត់ការឃោសនាព័ត៌មាន អគ្គបញ្ជាការដ្ឋាន

៤០-វរសេនីយ៍ទោ **ទិត ថៀន** អត្តលេខ ០០៤១៩១ នាយសេនាធិការរង យោធភូមិភាគទី ២ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤១-វរសេនីយ៍ទោ **ណាំ ចន្ទ្រះ** អត្តលេខ ០០៩៨១១ នាយកមន្ទីរពេទ្យ យោធភូមិភាគទី ២ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤២-វរសេនីយ៍ទោ **ខួច** **សុខរិទ្ធ** អត្តលេខ ០០២៨៨០ នាយកមន្ទីរពេទ្យ យោធភូមិភាគទី ៤ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៣-វរសេនីយ៍ទោ **ទ៉ែន** **សុខុម** អត្តលេខ ០០២១៨៣ នាយក មន្ទីរពេទ្យ យោធភូមិភាគទី ៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៤-វរសេនីយ៍ទោ **សុខ** **ស៊ុនសំបូរ** អត្តលេខ ០០៩៤៨២ នាយកការិយាល័យទំនាក់ទំនងសាធារណៈ ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន

៤៥-វរសេនីយ៍ទោ **ទ៉ែន** **ស៊ីមិន** អត្តលេខ ០០២៥៦៥ មេបញ្ជាការ កងរាជអាវុធហត្ថ ខេត្តកំពង់ស្ពឺ

៤៦-វរសេនីយ៍ទោ **អឿ** **សាម៉ន** អត្តលេខ ០០៩២៧៥ នាយករង សាលាកងរាជអាវុធហត្ថ កំបូល

៤៧-វរសេនីយ៍ទោ **នាង** **ចិន្ទ** អត្តលេខ ០១១៤៦៨ អង្គរក្សផ្ទាល់សម្តេច **ជា** **ស៊ីម** កងពលតូចលេខ ៧០

៤៨-វរសេនីយ៍ទោ **ពន្ស** **សារិទ្ធ** អត្តលេខ ០០៥២៣៩ មេបញ្ជាការរង កងរាជអាវុធហត្ថ រាជធានីភ្នំពេញ

៤៩-វរសេនីយ៍ទោ **អ៊ុក** **ឈុន** អត្តលេខ ០០១៤២៦ នាយកការិយាល័យនីតិកម្ម នាយកដ្ឋានបុគ្គលិក

៥០-វរសេនីយ៍ទោ **គឹម** **សារីឡាន់** អត្តលេខ ០០១៦៥៩ នាយ ការិយាល័យសហប្រតិបត្តិការ នាយកដ្ឋានទាក់ទងអន្តរជាតិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....០៤...សសរ

<u>សេចក្តីសម្រេច</u>

ស្តីពី

ការកែសម្រួលសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្តីជូនដំណឹងលេខ ១១៦៩ សជណ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១០ នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦
- យោងសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូ ពិភាក្សាការងារជាមួយផ្នែកឯកជន និងសេចក្តីសំរេចកែសំរួល៣៧ សសរ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦
- យោងសេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងសេចក្តីសំរេចកែសំរួលលេខ៣២ សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៥

- យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងសេចក្តីសំរេចកែសំរួលលេខ៣២ សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៥
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

សំរេច

ប្រការ១: កែសំរួលឈ្មោះក្រុមការងារ ដែលមានចែងក្នុងចំនុច "ច" ប្រការ១ នៃសេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន មកជា ***ក្រុមការងារផ្នែកថាមពល-ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន*** វិញ។

ប្រការ២: កែសំរួលសមាសភាពក្រុមការងារតំណាងរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ដែលមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូ ពិភាក្សាការងារជាមួយផ្នែកឯកជន និងសេចក្តីសំរេចលេខ៣៧ សសរ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសំរួលសេចក្តីសំរេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន មកជាសមាសភាព ដូចខាងក្រោមវិញ :

ក- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម :

១-	ឯកឧត្តម **ចាន់ សារុន**	រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សហប្រធាន
២-	ឯកឧត្តម **ឌិត ទីណា**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	អនុប្រធាន
៣-	ឯកឧត្តម **ម៉ឹង ម៉ីយ**	រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤-	ឯកឧត្តម **អេង ហួត**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៥-	ឯកឧត្តម **គឹម ស៊ីថន**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
៦-	ឯកឧត្តម **កែវ ខេមរា**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៧-	ឯកឧត្តម **យិន គីមសាន**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៨-	ឯកឧត្តម **ស្រ៊ុន តារា**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩-	ឯកឧត្តម **កួយ សុខារិទ្ធ**	អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១០-	ឯកឧត្តម **នូ តឿង**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
១១-	ឯកឧត្តម **សួន សិទ្ធី**	អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក

ខ- ក្រុមការងារផ្នែកទេសចរណ៍ :

១- ឯកឧត្តម **ឡាយ ប្រហាស** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហប្រធាន

២- ឯកឧត្តម **ស៊ុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣- ឯកឧត្តម **សេង លឹមនៅ** រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- ឯកឧត្តម **ប្រាជ្ញ ស៊ុន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៥- ឯកឧត្តម **ស៊ូ ម៉េងគា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦- ឯកឧត្តម **អ៊ុក សុជាតិ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៧- ឯកឧត្តម **ស៊ុខ សុនី** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៨- ឯកឧត្តម **ស៊ីម ស៊ូឡេង** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៩- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១០- ឯកឧត្តម **នេព ហែន** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក

១១- ឯកឧត្តម **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

គ- ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច-មធ្យម :

១- ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហប្រធាន

២- ឯកឧត្តម **ចំន្ទ នរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣- ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៤- ឯកឧត្តម **តឿង សុភ័ណ្ឌ** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៥- ឯកឧត្តម **អ៊ឹង តិរុន** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៦- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៧- ឯកឧត្តម **ឌី តាយី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨- ឯកឧត្តម **នា ជុំ** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៩- ឯកឧត្តម **តូច ចាន់កុសល** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១០- ឯកឧត្តម **សយ សុខា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១- ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

១២- ឯកឧត្តម **អ៊ិត ណាវី** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៣- ឯកឧត្តម **ស្រ៊ុន ចន្ទ្រវណ្ណៈ** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

ឃ. **ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច :**

១- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហប្រធាន

២- ឯកឧត្តម **គង់ វិបុល** រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម **ជា សុផារ៉ា** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៥- ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៦- ឯកឧត្តម **គីម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៧- លោកជំទាវ **ខ្វាក់ ចន្ថា** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៨- ឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៩- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០- ឯកឧត្តម **អ៊ុង ប៊ុណ្ណារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១១- ឯកឧត្តម **មាស គឹមសុទារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២- ឯកឧត្តម **សូ ម៉ារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

ង. **ក្រុមការងារផ្នែកសេវារាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ :**

១- ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សហប្រធាន

២- ឯកឧត្តម **ជា ប៉េងឈាង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម **ម៉ុម ស៊ីបុន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥- ឯកឧត្តម **ចន្ទ ហួន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៦- ឯកឧត្តម **ឯក វណ្ណឌី** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

៧- ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៨- ឯកឧត្តម **សុខ ផេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម **ជា សៃ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- ឯកឧត្តម **ទ៉ា ស៊ីមសារិទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១១- ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១២- ឯកឧត្តម **គីម សុភ័ណ្ណ** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៣- លោក **ឌីក វ៉េតសំរេច** ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

ច~ ក្រុមការងារផ្នែកថាមពល ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន :

១- ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សហប្រធាន
២- ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុប្រធាន
៣- ឯកឧត្តម **នេព នន្ធី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៤- ឯកឧត្តម **តាន់ ធុដ្ឋា** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
៥- ឯកឧត្តម **លី អៀមឡាក់** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៦- ឯកឧត្តម **ឆូច ហេង** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
៧- ឯកឧត្តម **ភើស សារ៉េត** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៨- ឯកឧត្តម **ម្លូង សៅខន** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៩- ឯកឧត្តម **ជា ឆាយ** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១០- ឯកឧត្តម **អេង សូស្តី** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
១១- ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក
១២- ឯកឧត្តម **ជា វ៉ាន់ដេត** ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

ឆ~ ក្រុមការងារផ្នែកផលិតកម្មកែច្នៃសំរាប់នាំចេញ និងកិច្ចសំរួលពាណិជ្ជកម្ម :

១- ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហប្រធាន
២- ឯកឧត្តម **សួន ហេង** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន អនុប្រធាន
៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
៤- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- ឯកឧត្តម **អូស្មាន់ ហាសាន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
៦- ឯកឧត្តម **ខ្លូត រ៉ាន់ឌី** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
៧- ឯកឧត្តម **ខៀវ មុត** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
៨- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ សមាជិក
៩- ឯកឧត្តម **ទ៉ា ជាង** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
១០- ឯកឧត្តម **អ៊ុក សុខុន** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១១- ឯកឧត្តម **ផា សុផ្លា** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
១២- ឯកឧត្តម **ហ៊ុយ ថូរ៉ាក់ស៊ី** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី សមាជិក

៩- **ក្រុមការងារផ្នែកទំនាក់ទំនងទីប្រជាជីវៈ**

១- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហប្រធាន

២- ឯកឧត្តម **ម៉ម សុនត** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម **សេង លីមនៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥- ឯកឧត្តម **ម៉ិន សម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦- ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៧- លោកជំទាវ **ចាន់ សុខ្នាវី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៨- ឯកឧត្តម **អ៊ឹ មាន** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៩- ឯកឧត្តម **ខុម សុវណ្ណារី** អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

១០- ឯកឧត្តម **សាត សាមី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១១- ឯកឧត្តម **ស៊ឹម សួន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១២- ឯកឧត្តម **ឃួន វ៉ាលីន** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៣- ឯកឧត្តម **ទៃ សុខខេង** អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

១៤- ឯកឧត្តម **ឆយ អួន** សមាជិកក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៥- លោកជំទាវ **ជូ បុនអេង** អគ្គនាយកបច្ចេកទេសក្រសួងកិច្ចការនារី សមាជិក

១៦- លោក **ឡោក់ ខាងអមិដា** អគ្គនាយករងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៧- ឧត្តមសេនីយឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រសួងមហាផ្ទៃ) សមាជិក

ប្រការ៣: កែសំរួល សមាសភាពអនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចលេខ៤៦ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតអនុគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន មកជាសមាសភាពដូចខាងក្រោមវិញ :

ក- **អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ :**

១- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៣- ឯកឧត្តម **ឡៅ អ៊ុចតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៤- ឯកឧត្តម អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៥- ឯកឧត្តម ឆាំង សុខសំភ្ន រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៦- ឯកឧត្តម ឡា ណារ៉ាត រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

៧- ឯកឧត្តម នុត ណារ៉ាង រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៨- លោកជំទាវ ចំនួ គុនអ៊ីទ្ធ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៩- លោក ចាន់ សុធី ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការ

ខ. **អនុគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម** :

១- ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន

២- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម ព្រឿ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៤- ឯកឧត្តម ខួត រ៉ាន់ឌី រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៥- ឯកឧត្តម តេង ឡៅ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦- ឯកឧត្តម អ៊ឹង ភិរុន រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៧- ឯកឧត្តម ជ្វី អៀក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៨- ឯកឧត្តម ម៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ សមាជិក

៩- ឯកឧត្តម ទាំ ជាង អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម លេខាធិការ

គ. **អនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម** :

១- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាន

២- ឯកឧត្តម ចំនួ នរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣- ឯកឧត្តម យឹម ទៀនថន រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៤- ឯកឧត្តម អ៊ុំ ម៉ុនឡុង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម ម៉ោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៦- ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៧- ឯកឧត្តម អ៊ិន ចន្ថា រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៨- លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

៩- ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

១០- ឯកឧត្តម ខួន ម៉េងតិច អគ្គនាយក សភាពាណិជ្ជកម្មកម្ពុជា សមាជិក

១១- ឯកឧត្តម កែវ រតនៈ អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខាធិការ

ប្រការ៤: ក្រៅពីការកែសំរួលដូចមានក្នុងប្រការ១ ប្រការ២ និងប្រការ៣ខាងលើ ខ្លឹមសារផ្សេងៗទៀតនៃសេចក្តីសំរេចលេខ៤៧សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន សេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតអនុគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងសេចក្តីសំរេចលេខ ៣៧ សសរ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសំរួលសេចក្តីសំរេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន នៅមានសុពលភាពអនុវត្តដដែល ។

ប្រការ៥ : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី -រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -រដ្ឋមន្ត្រីគ្រប់ក្រសួង -គ្រប់អភិបាលខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១៤៦៥ សហវ.ហក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

ប្រកាស
ស្តីពី
ការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាលក្នុងការពិនិត្យសំរេចចុះនិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអំពីប្រពន្ធ័ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៦សហវ-ប្រក ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញកិច្ច
- ផ្អែកតាមសកម្មភាព ៦.១.១ ស្ដីពីការពិនិត្យឡើងវិញលើបទបញ្ញាប្រកាសដែលកំពុងអនុវត្តលើការផ្ដល់សិទ្ធិធានាចំណាយ និងអាណត្តិទូទាត់ ក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

<u>សម្រេច</u>

ប្រការ១ : ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវចុះទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួង ស្ថាប័នរដ្ឋបាលកណ្ដាល សំរាប់មុខចំណាយមួយចំនួនដូចខាងក្រោម ÷

- ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យាឬបុគ្គលិកអណ្ដែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- មន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន
- មរណៈភាព
- ឧបត្ថម្ភម្ដងគត់ជូននិវត្តជន
- ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ
- ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ
- អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស។

ប្រការ២ : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន មានសិទ្ធិសំរេចទទួលខុសត្រូវចុះទិដ្ឋាការចំពោះមុខចំណាយមួយចំនួនដូចមានចែងក្នុងប្រការ ១ ខាងលើ ទៅតាមចំនួនទឹកប្រាក់ដូចខាងក្រោម ÷

- ***មិនមានកំណត់ចំនួនទឹកប្រាក់សំរាប់មុខចំណាយ ÷***

+ ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

+ ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកអណ្តែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- ***ក្រោមចំនួនទឹកប្រាក់ ៥០ លានរៀល សំរាប់មុខចំណាយដែលមានលក្ខណៈដូចខាងក្រោម ÷***

+ ឧបត្ថម្ភមន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន

+ ឧបត្ថម្ភមរណៈភាព

+ ឧបត្ថម្ភម្តងគត់ជូននិវត្តជន

+ ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ

+ ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ

+ អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស ។

ប្រការ៣ : ភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាលមានដូចខាងក្រោម ÷

- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ សមស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងសារាចរណែនាំលេខ, ០០៥ សហវ-ហ.សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

- មិនអនុញ្ញាតឱ្យធ្វើការបំបែកគំរោងចំណាយ ទៅជាគំរោងចំណាយតូចៗ ដើម្បីគេចវៀរទៅតាមកំរិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិសំរេច ។

- ត្រួតពិនិត្យជាមុនអំពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយ ជាពិសេសត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការធានាចំណាយជាមួយនឹងឥណទានទំនេរ និងផ្ទៀងផ្ទាត់រវាងការបញ្ចេញអាណត្តិទូទាត់ជាមួយនឹងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។

- ត្រួតពិនិត្យពីភាពត្រឹមត្រូវនៃលិខិតយុត្តិការ (សក្ខីប័ត្រ) ដែលទាក់ទងនឹងសំណុំរឿងស្នើសុំចំណាយមុននឹងធ្វើការទូទាត់ ។

- ផ្តល់ការណែនាំអំពីនីតិវិធីចំណាយចំពោះផ្នែកនានារបស់អាណាប័ក ក្នុងគោលបំណងបង្ការទុកជាមុននូវភាពមិនប្រក្រតី ដើម្បីចៀសវាងចំណាយគ្មានគម្លាភាព ឬចំណាយលើសពីឥណទានអនុម័តដែលធ្វើឱ្យរដ្ឋជំពាក់បំណុលគេ ។

- ត្រូវធ្វើការសិក្សាស្វែងយល់អំពីគោលនយោបាយជាអាទិភាពរបស់ក្រសួងសាមី ដើម្បីបង្កើនលទ្ធភាពឱ្យអាណាប័កចំណាយតាមឥណទានថវិកាដែលបានអនុម័ត ។ ប៉ុន្តែក៏ត្រូវអនុវត្តយ៉ាងហ្មត់ចត់នូវវិន័យថវិកា និងតាមលិខិតបទដ្ឋានដែលមានចែងជាធរមាន ។
- កាន់កាប់បញ្ជីគណនេយ្យធានាចំណាយ និងអាណត្តិកិច្ចឱ្យបានទៀងទាត់ និងត្រឹមត្រូវ ដោយធ្វើការផ្ទៀងផ្ទាត់តួលេខអោយស៊ីគ្នាជាប្រចាំជាមួយនឹងផ្នែកគណនេយ្យរដ្ឋបាលរបស់អាណាប័ក និងជាមួយនឹងផ្នែកចំណាយរបស់រតនាគារជាតិ ។
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍អំពីការអនុវត្តនីតិវិធីសំរេចទទួលខុសត្រូវរបស់ខ្លួន ទាំងការធានាចំណាយ ទាំងការបញ្ចេញអាណត្តិជូននាយកដ្ឋានហិរញ្ញកិច្ចឱ្យបានទៀងទាត់ ដើម្បីធ្វើការបូកសរុប ។

ប្រការ៤ : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន ត្រូវមានស្មារតីសាមគ្គីភាព និងរក្សានូវសីលធម៌វិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ។

ប្រការ៥ : រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦ : អគ្គលេខាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន ព្រមទាំងប្រធាននាយកដ្ឋាន អង្គភាពពាក់ពន្ធ័ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

ទេសរដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួងស្ថាប័នដែលមានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅអមផ្ទាល់
  "ដើម្បីសហការអនុវត្ត"
- គ្រប់នាយកដ្ឋាន អង្គភាព ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពាក់ពន្ធ័ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ និងកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៤១១...សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ៥ ឆ្នាំ ២០០៦

ប្រកាស
ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone . 855-23-724 664 Fax : 855-23-427 798

សំរេច

ប្រការ១ : តណាទានចំណូលនៃថវិកាទូទៅរបស់រដ្ឋ ដូចមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ហើយដែលត្រូវបានបែងចែកតាមជំពូក ដោយអនុក្រឹត្យលេខ ១៧០ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក ត្រូវបានបែងចែកលំអិតនៅក្នុង គណនី និង អនុគណនី ។ ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ត្រូវមានភារកិច្ចប្រមូលចំណូលបង់ចូលថវិការដ្ឋ ដូចមានចែងក្នុងសៀវភៅថវិកា ដែលភ្ជាប់មកជាមួយប្រកាសនេះ ។

ប្រការ២ : រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ជាអ្នកទទួលបន្ទុកប្រមូល ចំណូលអោយបានតាមគំរោង ឬ លើសគំរោង ដើម្បីជាគុណប្រយោជន៍ដល់ថវិកាទូទៅរបស់រដ្ឋ ។

ប្រការ៣ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០៧ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាពត៌មាន"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង – រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នាយកដ្ឋានថវិកា

ការិយាល័យរដ្ឋបាល និង សរុបថវិកា

ការគ្រប់គ្រងឆ្នាំ ២០០៧

ថវិកាទូទៅរបស់រដ្ឋ

សៀវភៅថវិការដ្ឋបាលកណ្តាល

ការគ្រប់គ្រងឆ្នាំ ២០០៧
ចំណូលថវិកាចរន្តរបស់រដ្ឋ

ការពិព្រាយពេលាន និង សាវចរិយា

ឯកតា : លានរៀល

ជំពូក	គណនី	អនុគណនី	ការបរិយាយមុខចំណូល	សរុបរួម	សរុបថវិកាកណ្តាល	សរុប ខេត្ត ក្រុង	10.1 គយ និង រដ្ឋាករ	10.1 ពន្ធដារ	10.1 ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	01.1 ក្រសួង ព្រះបរមរាជវាំង	05.1 ទីស្តីការ គណៈរដ្ឋមន្ត្រី	05.3 រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល	05.4 ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា	06.1 ក្រសួងការពារជាតិ	07.1 ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ	09.1 ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	11.1 ក្រសួងព័ត៌មាន	12.1 ក្រសួងសុខាភិបាល	13.1 ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	15.1 ក្រសួងពាណិជ្ជកម្ម	16.1 ក្រសួងអប់រំ យុវជន និង កីឡា	17.1 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	18.1 ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	19.1 ក្រសួងបរិស្ថាន	20.1 ក្រសួងអភិវឌ្ឍន៍ជនបទ
			សរុបចំណូលថវិកាចរន្តរបស់រដ្ឋ	4.622.305,5	4.606.693,7	15.611,8	1.771.000,0	790.000,0	1.535.768,1	400,0	84.960,0	50.133,6	600,0	1.260,0	70.165,0	37.897,0	1.256,0	1.920,0	14.102,0	79.051,0	680,0	35.203,0	2.135,0	270,0	
			ក្នុងនោះ ចំណូលក្នុងប្រទេស	3.282.172,5	3.266.560,7	15.611,8	1.771.000,0	790.000,0	195.635,1	400,0	84.960,0	50.133,6	600,0	1.260,0	70.165,0	37.897,0	1.256,0	1.920,0	14.102,0	79.051,0	680,0	35.203,0	2.135,0	270,0	
			ក. សរុបចំណូលស្ថូវគ្គី	3.252.172,5	3.236.560,7	15.611,8	1.771.000,0	790.000,0	165.635,1	400,0	84.960,0	50.133,6	600,0	1.260,0	70.165,0	37.897,0	1.256,0	1.920,0	14.102,0	79.051,0	680,0	35.203,0	2.135,0	270,0	
			ជំពូកទី១: ចំណូលពិត	3.252.172,5	3.236.560,7	15.611,8	1.771.000,0	790.000,0	165.635,1	400,0	84.960,0	50.133,6	600,0	1.260,0	70.165,0	37.897,0	1.256,0	1.920,0	14.102,0	79.051,0	680,0	35.203,0	2.135,0	270,0	
			ជំពូករងទី១: ចំណូលសារពើពន្ធ	2.682.000,0	2.682.000,0		1.771.000,0	790.000,0	66.000,0											55.000,0					
70			ចំណូលសារពើពន្ធក្នុងប្រទេស	1.857.540,0	1.857.540,0		1.001.540,0	790.000,0	66.000,0																
	700		ពន្ធលើផលចំណេញ ប្រាក់ចំណេញ និង កំរៃទុន (រូបវន្តបុគ្គល)	72.200,0	72.200,0			72.200,0																	
		7001	ពន្ធលើប្រាក់បៀវត្ស	52.000,0	52.000,0			52.000,0																	
	618		សោហ៊ុយពិធីផ្សេងៗ	183,0				131,5				15,0	5,0				24,0	0,5				5,0				2,0
		181	សំភារៈ និង ពិធីបុណ្យ	183,0				131,5				15,0	5,0				24,0	0,5				5,0				2,0
62			សោហ៊ុយផ្សេងៗ	35.829,5	527,0	854,0	617,0	11.476,0	577,1	570,0	709,8	4.854,0	2.668,5	897,0	629,0	3.061,5	1.671,0	502,8	511,0	1.125,0	1.033,6	918,0	624,2	539,7	505,3	958,0
	621		បុគ្គលិកខាងក្រៅ	2,5					2,0													0,5				

ការគ្រប់គ្រងឆ្នាំ ២០០៧

ចំណាយថវិកាចរន្តរបស់រដ្ឋ

សរុបរួមឥណទានតាមវិស័យរបស់ក្រសួង-ស្ថាប័ន

[illegible]

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបរួម	ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព័ត៌មាន	សុខាភិបាល	ឧស្សាហកម្ម រ៉ែ និង ថាមពល	ផែនការ	ពាណិជ្ជកម្ម	អប់រំ យុវជន និង កីឡា	កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	វប្បធម៌ និង វិចិត្រសិល្បៈ	បរិស្ថាន	អភិវឌ្ឍន៍ជនបទ	សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	ប្រៃសណីយ៍ និង ទូរគមនាគមន៍	ធម្មការ និង សាសនា	កិច្ចការនារី	សាធារណការ និង ដឹកជញ្ជូន	យុត្តិធម៌	ទេសចរណ៍	រៀបចំដែនដី នគរូបនីយកម្ម និង សំណង់	ធនធានទឹក និង ឧតុនិយម	ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
62	621	6211	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	2,0					2,0																	
		6213	បុគ្គលិក-សេវាកម្មសាធារណៈផ្សេងៗ	0,5																		0,5				
	622		ទំនាក់ទំនងសាធារណៈ និង ផ្សព្វផ្សាយ	7.688,9	126,3	215,7	147,1	2.446,5	109,6	79,7	129,9	905,9	598,9	174,7	92,7	616,3	845,8	75,5	75,0	261,6	150,3	108,5	105,4	88,3	99,4	235,8
		6221	សោហ៊ុយទទួលភ្ញៀវជាតិ	2.782,7	55,4	146,1	49,7	709,4	68,9	47,4	86,6	255,9	263,3	67,3	45,7	307,9	77,8	46,0	34,5	84,1	90,1	68,5	68,4	63,3	53,3	93,1
		6222	សោហ៊ុយទទួលភ្ញៀវបរទេស	495,6	3,3	0,8		165,3	5,2	5,0	6,2	67,3	56,7	1,2	0,6	100,2	11,7	3,2	1,5	11,5	7,0	8,3	5,0	5,3	12,3	18,0
		6223	ប្រជុំ សិក្ខាសាលា និង សន្និសីទ	2.271,7	5,6	59,3	21,3	823,3	31,6	21,4	33,6	462,0	175,0	57,8	24,4	197,6	38,7	22,3	29,7	69,9	42,0	23,4	26,4	16,8	29,3	60,3
		6224	សោហ៊ុយពិធីបុណ្យ	1 340,5	0,5	9,5	3,0	181,7	3,5	5,9	3,5	115,2	43,2	42,2	21,0	10,6	710,1	4,0	9,3	93,6	4,2	7,3	5,6	2,9	4,5	59,2
			. បុណ្យជាតិ និង បុណ្យប្រពៃណី	364,2	0,5	5,8	3,0	140,2	3,5	4,9	2,5	64,2	33,7	7,4	4,2	10,6	36,5	4,0	3,0	14,0	4,2	6,8	4,6	2,9	4,5	3,2
			បុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ	14,7				12,5				1,5		0,2								0,5				
			. បុណ្យ[illegible]	1,0																1,0						
			. បុណ្យផ្សេងៗទៀត	960,6		3,7		29,0		1,0	1,0	49,5	9,5	34,6	16,8		673,6		6,3	78,6			1,0			56,0
		6225	ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និង ក្រៅប្រទេស	5,0				5,0																		
		6226	សោហ៊ុយសំរាប់ការតាំងពិព័រណ៍នៅក្នុង និង ក្រៅប្រទេស	51,1					0,4				50,7													
		6227	ការឃោសនា និង ផ្សព្វផ្សាយព័ត៌មានសាធារណៈ	742,3	61,5		73,1	561,8				5,5	10,0	6,2	1,0		7,5			2,5	7,0	1,0				5,2
	623		សោហ៊ុយជាវសារព័ត៌មាន និង ឯកសារ	212,1	4,2	12,1	14,0	52,9	2,0	3,9	11,5	35,4	10,3	5,8	2,5	19,4	4,5	2,4		6,0	9,8	6,4	4,5		0,5	4,0
	624		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស	25.614,2	352,7	537,8	419,5	8.399,2	412,6	439,9	507,5	3.615,4	1.864,7	671,6	497,1	2.276,6	712,6	372,2	400,6	763,0	780,6	735,8	478,4	382,0	348,7	645,7
		6241	សោហ៊ុយដឹកជញ្ជូន	2.857,9	54,1	90,3	73,2	468,5	56,3	74,8	74,2	466,3	197,6	80,7	79,7	261,0	113,4	53,4	55,0	99,4	144,0	92,1	101,6	77,7	43,5	101,1
		6242	សោហ៊ុយបេសកកម្ម	7.147,3	62,9	84,8	86,2	3.462,1	83,1	81,5	80,1	938,3	425,0	109,7	106,8	506,6	139,1	60,6	80,3	158,4	135,5	184,5	74,0	70,2	87,4	130,2
		6243	សោហ៊ុយស្នាក់នៅ	15 609,0	235,7	362,7	260,1	4 468,6	273,2	283,6	353,2	2.210,8	1.242,1	481,2	310,6	1.509,0	460,1	258,2	265,3	505,2	501,1	459,2	302,8	234,1	217,8	414,4
	626		សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទគេហ៊ឹប និង	2.311,6	43,8	88,4	36,4	577,4	50,9	46,5	60,9	297,3	194,4	44,9	36,7	149,2	108,1	52,7	35,4	94,4	92,9	66,8	35,9	69,4	56,7	72,5
		6261	សោហ៊ុយប្រៃសណីយ៍	58,6	2,5			7,0	0,5	1,7	2,0	14,2	2,3	0,7	0,1	2,0	5,0	1,8		10,5	1,1	5,5	1,0	0,5		0,2
		6262	សោហ៊ុយទូរគមនាគមន៍	2.253,0	41,3	88,4	36,4	570,4	50,4	44,8	58,9	283,1	192,1	44,2	36,6	147,2	103,1	50,9	35,4	83,9	91,8	61,3	34,9	68,9	56,7	72,3
	627		សោហ៊ុយធនាគារ	0,2									0,2													
64			បន្ទុកបុគ្គលិក	508.170,4	915,0	1.723,0	1.999,0	38.318,0	2.483,0	2.505,0	1.552,0	322.154,0	5.698,4	3.646,0	2.010,0	3.223,0	91.320,0	1.413,0	2.527,0	2.155,0	7.214,0	7.464,0	1.820,0	3.457,0	1.562,0	3.012,0
	642		លាភការ និង ប្រាក់ចំណាយបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍	388 805,2	752,2	1.469,6	1.605,7	33.756,1	2.165,7	2.143,1	1.315,5	306.732,6	4 879,8	2.728,7	1.795,4	2.668,4	2.812,1	1.257,0	2.003,2	1.725,4	3.978,3	6.890,2	1.196,5	3.120,7	1.382,3	2.426,7
		6421	ប្រាក់បៀវត្សមូលដ្ឋាន	172.552,5	412,6	903,4	1.018,6	16.564,7	1.435,0	1.374,5	853,6	126.399,3	3.737,5	2.057,4	1.136,5	1.847,1	1.919,5	802,8	910,2	1.110,8	3.017,6	1.709,6	790,0	2.221,0	936,3	1.394,5
		6422	ប្រាក់បំណាច់មុខងារ	156.873,2	337,5	560,8	580,9	11.366,0	722,7	759,1	456,9	128.008,1	1.121,7	659,8	651,0	809,2	866,1	447,8	513,8	605,2	942,5	4.830,5	401,1	888,1	440,8	923,6
		6423	ប្រាក់បំណាច់ផ្សេងៗ[illegible]	45.935,4			18,5	4.651,1				40.326,0					15,0		549,8			345,3				29,7
		6424	ប្រាក់កំរៃគ្រូបង្រៀន	11.519,5								11.425,1							23,9							70,5
		6425	ប្រាក់បំប៉នជីវភាព[illegible]	0,1										0,1												

ការគ្រប់គ្រងឆ្នាំ ២០០៧
ចំណាយចរន្តតាមក្រសួងរបស់រដ្ឋ
សរុបរួមចំណាយតាមចំណាត់ថ្នាក់របស់ក្រសួង-ស្ថាប័ន

ការអធិប្បាយ: លោមាន និង សារបញ្ជីថវិកា

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុប	ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព័ត៌មាន	សុខាភិបាល	ឧស្សាហកម្ម រ៉ែ និង ថាមពល	ផែនការ	ពាណិជ្ជកម្ម	អប់រំ យុវជន និង កីឡា	កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	វប្បធម៌ និង វិចិត្រសិល្បៈ	បរិស្ថាន	អភិវឌ្ឍន៍ជនបទ	សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	ប្រៃសណីយ៍ និង ទូរគមនាគមន៍	ធម្មការ និង សាសនា	កិច្ចការនារី	សាធារណការ និង ដឹកជញ្ជូន	តុលាការ	ទេសចរណ៍	រៀបចំដែនដី នគរូបនីយកម្ម និង សំណង់	ធនធានទឹក និង ឧតុនិយម	ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
64	642	6126	ប្រាក់បំណាច់តំបន់	830,3	2,0	4,8	6,1	98,0	6,9	8,5	4,8	568,3	19,7	10,8	7,7	11,9	9,9	5,5	5,0	9,1	17,5	3,9	4,9	11,6	5,1	8,3
		6127	ប្រាក់បំណាច់ទទួលខុសត្រូវ	0,9								0,3						0,1				0,4	0,1			
		6128	ប្រាក់បំណាច់ការងារធ្ងន់ និង បំពុលសុខភាព	1.093,3	0,1	0,6	1,6	1.076,3	1,1	1,0	0,2	5,5	0,9	0,6	0,2	0,2	1,6	0,8	0,5	0,3	0,7	0,5	0,4		0,1	0,1
	643		រង្វាន់និងប្រាក់បំណាច់ផ្សេងៗទៀត	1.476,2		16,8	5,3	924,0	8,8	6,5	2,3	248,2		41,8	5,0	12,5	5,0		4,8		13,4	151,8	15,5	10,5		4,0
		6131	កម្រៃអាទិភាព	871,5		16,8	5,3	550,0	8,8	6,5	2,3	194,1		35,8		12,5					13,4		15,5	10,5		
		6132	ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង	400,2				374,0				15,4							4,8			6,0				
		6133	រង្វាន់	44,7								38,7		6,0												
		6134	ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ	138,8																		138,8				
		6135	អាហារសំរាប់បុគ្គលិករដ្ឋ	11,0																		7,0				4,0
		6138	ផ្សេងៗ	10,0											5,0		5,0									
	644		ឈ្នួល និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និង	10.145,3	80,1	11,3	151,9	1 792,9	61,4	107,6	45,0	2.655,0	143,5	595,4	20,5	144,2	241,9	16,9	303,4	233,8	2.604,3	75,0	490,1	8,2	12,5	350,4
		6141	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ	4 635,1	43,8	3,4	10,5	480,4	48,9	37,5	15,5	2.508,8	33,2	184,6		72,9	166,6	13,6	303,4	202,4	20,2	29,2	199,6	4,8		255,8
		6142	លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ	26,4								7,5										18,9				
		6143	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	5.483,8	36,3	7,9	141,4	1.312,5	12,5	70,1	29,5	138,7	110,3	410,8	20,5	71,3	75,3	3,3		31,4	2.584,1	26,9	290,5	3,4	12,5	94,6
	645		ប្រាក់វិភាជន៍សង្គម	107.743,7	82,7	225,3	236,1	1.845,0	247,1	247,8	189,2	12.518,2	675,1	280,1	189,1	397,9	88.261,0	139,1	215,6	195,8	618,0	347,0	117,9	317,6	167,2	230,9
		6151	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ	8.643,3	21,3	59,5	80,1	806,0	91,4	93,1	49,6	6.004,2	274,0	100,6	87,6	128,4	106,0	62,2	61,8	39,3	210,8	74,6	35,3	131,2	78,0	48,3
			. កូនមានអាយុតិចជាង១៨ ឆ្នាំ	5.065,5	10,1	29,3	41,5	484,5	44,8	53,3	20,0	3.645,9	146,5	48,2	49,6	68,4	54,3	32,6	28,4	23,2	98,6	36,6	17,9	66,9	43,1	21,8
			. កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ	1.335,7	4,1	13,1	15,2	109,4	17,2	13,2	13,1	905,3	34,3	21,9	13,7	17,9	22,2	10,7	15,6	8,3	42,9	12,2	6,1	19,5	10,9	8,9
			. ប្រាក់បំណាច់អ្នកក្នុងបន្ទុក	2.242,1	7,1	17,1	23,4	212,1	29,4	26,6	16,5	1.453,0	93,2	30,5	24,3	42,1	29,5	18,9	17,8	7,8	69,3	25,8	11,3	44,8	24,0	17,6
		6152	មន្ត្រីមានជំងឺ និង ឧបត្ថម្ភអ្នកសំរាលកូន	4.694,6	56,5	118,8	68,9	432,2	63,0	83,7	60,1	2.436,4	168,7	75,7	55,0	141,9	147,4	52,6	60,2	98,8	153,9	79,0	59,1	94,6	45,7	142,4
		6153	មរណភាព	11.398,1	3,0	7,6	12,3	153,8	17,7	6,6	8,6	1 054,3	58,1	26,8	9,9	25,8	9.873,1	6,3	7,9	10,6	51,2	9,4	1,7	20,7	15,5	17,2
		6154	ឧបត្ថម្ភនិវត្តជន	36.819,2	0,4	33,2	64,5	242,1	50,1	53,1	62,1	2.319,4	132,0	63,3	35,1	60,0	33 167,7	11,3	71,2	30,9	155,5	161,5	14,3	67,7	16,3	7,5
		6155	ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ	703,3		0,5	6,8	103,2	16,0	7,3	6,7	464,4	16,4	7,5		7,4	14,0		10,0	4,0	8,3	13,0	5,5	0,5	4,4	7,4
		6156	គ្រោះថ្នាក់ក្នុងការងារ និង [illegible]	44.351,1	1,5	5,7	3,5	60,4	8,4	4,0	2,1	147,9	16,5	6,2	1,5	32,2	43.978,0	6,7	4,5	6,2	38,1	9,5	2,0	2,9	7,3	8,0
		6157	ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ	869,5				32,7	0,5			91,6	9,4			2,2	724,8			6,0	2,2					0,1
		6158	ផ្សេងៗ	264,6				14,6									250,0									
ប្រភេទទី២: បន្ទុក[illegible]																										
ប្រភេទទី៣: អន្តរាគមន៍សាធារណៈ				34.095,0				3.850,0	935,0	3,0		5.500,0	4.386,0	3,0			13.675,0		1,0	1.242,0					4.100,0	400,0
65			ឧបត្ថម្ភធន [illegible]	34.095,0				3.850,0	935,0	3,0		5.500,0	4.386,0	3,0			13.675,0		1,0	1.242,0					4.100,0	400,0
	655		ឧបត្ថម្ភធនដល់[illegible]សាធារណៈ	9.421,0					935,0				4.386,0												4.100,0	

ការគ្រប់គ្រងឆ្នាំ ២០០៧

ចំណាយថវិកាថ្នាក់កណ្តាល

សរុបរួមឥណទានតាមវិស័យរបស់ខេត្ត-ក្រុង

ការអធិប្បាយ: មេធាន និង សារចរ័ឋាភិកា

ឯកតា : លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបរួម	ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព័ត៌មាន	សុខាភិបាល	ឧស្សាហកម្មរ៉ែ និង ថាមពល	ផែនការ	ពាណិជ្ជកម្ម	អប់រំ យុវជន និង កីឡា	កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	វប្បធម៌ និង វិចិត្រសិល្បៈ	បរិស្ថាន	អភិវឌ្ឍន៍ជនបទ	សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	ប្រៃសណីយ៍ និង ទូរគមនាគមន៍	ធម្មការ និង សាសនា	កិច្ចការនារី	សាធារណការ និង ដឹកជញ្ជូន	តុលាការ	ទេសចរណ៍	រៀបចំដែនដី នគរូបនីយកម្ម និង សំណង់	ធនធានទឹក និង ឧតុនិយម	ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
65	655	6551	ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈមិនមានលក្ខណៈហិរញ្ញ	9.421,0					935,0				4.386,0												4.100,0	
			• ឧបត្ថម្ភធនផ្សេងៗជាប្រចាំអោយសហគ្រាស	9.421,0					935,0				4.386,0												4.100,0	
	657		ជំនួយសង្គម និង ប្រាក់វិភាជន៍	14.331,2				3791,0		3,0		1.170,2		3,0			9.214,0		1,0	3,0						146,0
		6571	ជំនួយដល់ប្រជាជនរងគ្រោះ	1.355,5				347,5		3,0		7,0		3,0			991,0		1,0	3,0						
		6572	ឱសថ	805,7				805,7																		
		6573	អាហារ និង សំភារៈ	2 572,8				2.554,8				18,0														
		6574	ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ	8.223,0													8.223,0									
		6576	អាហារូបករណ៍សិក្សាការសិក្សា និង ស្រាវជ្រាវក្នុងប្រទេស	1.296,2				83,0				1.077,2														136,0
		6577	អាហារូបករណ៍សិក្សាការសិក្សា និង ស្រាវជ្រាវក្រៅប្រទេស	22,0								22,0														
		6578	ផ្សេងៗ	56,0								46,0														10,0
	658		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និង វប្បធម៌	10.342,8				59,0				4.329,8					4.461,0			1 239,0						254,0
		6581	ឧបត្ថម្ភសហគមន៍	1.258,0																1.238,0						20,0
		6582	ឧបត្ថម្ភមណ្ឌលកុមារកំព្រា	1.949,2													1.949,2									
		6583	ឧបត្ថម្ភដំណើរលំហែ និង សិក្សា	419,7				14,0				389,7														16,0
		6584	ឧបត្ថម្ភកាកបាទក្រហម	1,0																1,0						
		6585	ឧបត្ថម្ភសហគមន៍កីឡា និង វប្បធម៌	3.985,1				45,0				3.940,1														
		6586	ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និង	2.729,8													2.511,8									218,0
ប្រភេទទី៥: ចំណាយផ្សេងៗ				41,0				21,0				8,0				3,0				3,0	6,0					
63			ពន្ធ និង អាករ	41,0				21,0				8,0				3,0				3,0	6,0					
	631		លតាប័ត្រ	41,0				21,0				8,0				3,0				3,0	6,0					
ក្រុមទី២ ចំណាយតាមជីកា និង ចំណាយមិនបានគ្រោងទុក																										
ប្រភេទទី៥: ចំណាយតាមជីកា (មិនទូទាត់ប្រាក់)																										
ប្រភេទទី៦: ចំណាយមិនបានគ្រោងទុក																										
១. សរុបចំណាយចរន្តខេត្ត																										

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០១.....សហវ.ប្រក

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

ប្រកាស

ស្តីពី

ការកែសម្រួលអត្រាពន្ធគយ និង អត្រាអាករពិសេសលើទំនិញនាំចូលមួយចំនួន

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យក្រមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជាលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤៤ សហវ.ប្រក.គរ ចុះថ្ងៃទី ១៧ ខែ វិច្ឆកា ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៤
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៦ លើលិខិតលេខ ៧៨២៣ សហវ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច ៖

ប្រការ ១ ៖ ត្រូវបានកែសម្រួល អត្រាពន្ធគយ ដប់ប្រាំភាគរយ (១៥%) លើមុខទំនិញនាំចូលមួយចំនួនដែលមានចែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន និងមានលេខសម្គាល់ទីតាំងរងលេខ **២២.០៤, ២២.០៥, ២២.០៦, ២២.០៧** និងទីតាំងរងលេខ **២២.០៨** ។

ប្រការ ២ ៖ ត្រូវបានកែសម្រួល អត្រាអាករពិសេស ដប់ភាគរយ (១០ %) លើមុខទំនិញនាំចូលមួយចំនួនដែលមានចែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន និងមានលេខសម្គាល់ទីតាំងរងលេខ **២២.០៤, ២២.០៥, ២២.០៧, ២២០៨.២០, ២២០៨.៣០, ២២០៨.៤០, ២២០៨.៥០, ២២០៨.៦០,** និងទីតាំងរងលេខ **២២០៨.៧០** ។

ប្រការ ៣ ៖ ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ ៖ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ព្រមទាំងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចំពោះទំនិញដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូនឯបរទេស ដើម្បីនាំចូលមកព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ទីចាត់ការគយ និងរដ្ឋាករ
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
  " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៩៨ សហវ

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬអាយុជីវិត

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើប្រាស់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីការណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ បក ចុះថ្ងៃទី ២០ ខែមករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ២០០០ បំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសំរួលការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ជំពូក ១ : បទប្បញ្ញត្តិទូទៅ

ប្រការ ១ : តាមការឱ្យនិយមន័យនៅក្នុងជំពូក១ នៃច្បាប់ស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងគឺជានីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលហានិភ័យធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រង ហើយនិងត្រូវទទួលអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលចាប់ផ្តើមអាជីវកម្ម ។

ប្រការ ២ : អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណធានារ៉ាប់រង ត្រូវជ្រើសរើសយកទម្រង់គតិយុត្តិមួយ ដែលមានចែងនៅក្នុងជំពូក ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។ ចំពោះក្រុមហ៊ុនធានារ៉ាប់រងថ្មីដែលនិងទទួលអាជ្ញាប័ណ្ណក្រោមខ្លឹមសារនៃប្រកាសនេះ ត្រូវមានភាគទុនិកយ៉ាងតិច ៣ ។

ប្រការ ៣ : មុនពេលទទួលអាជ្ញាប័ណ្ណ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានបំពេញតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រាទី ៤៨ នៃច្បាប់ស្តីពីការធានារ៉ាប់រង ដូចខាងក្រោមនេះ :

ក- បានរក្សាប្រាក់ដំកល់ចំនួនស្មើនឹងដប់ (១០)ភាគរយនៃដើមទុនចុះបញ្ជី។

ខ- បានរក្សាកិតសាធនភាពចំនួនស្មើនិង ហាសិប (៥០)ភាគរយនៃដើមទុនចុះបញ្ជី។

ជំពូក ២ : នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ និងការសុំបន្តអាជ្ញាប័ណ្ណ

ប្រការ ៤ : បុគ្គលដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ (សមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយក ឬបុគ្គលផ្សេងទៀតដែលមានសិទ្ធិក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ) ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ដោយបំពេញទម្រង់បែបបទ ដែលទទួលពីនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវបង្ហាញពតិមានដូចតទៅ :

ក- ពតិមានអំពីក្រុមហ៊ុន

១) ឈ្មោះក្រុមហ៊ុនធានារ៉ាប់រង ។

២) អាស័យដ្ឋានរបស់ទីស្នាក់ការកណ្តាលក្រុមហ៊ុន ឬការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣) ទម្រង់គតិយុត្តិ លក្ខន្តិកៈបង្កើតក្រុមហ៊ុន បទបញ្ជាផ្ទៃក្នុង ឬ លិខិតបទដ្ឋានផ្សេងទៀត។

៤) ប្រភេទមូលប័ត្រដែលជាដើមទុននិងទំនាក់ទំនងរវាងម្ចាស់មូលប័ត្រ និងការអនុវត្តន៍សិទ្ធិបោះឆ្នោត។

៥) ចំនួនទឹកប្រាក់ដើមទុនចុះបញ្ជីដែលមានស្រាប់ ដើមទុនចុះបញ្ជីដែលគ្រោងទុក និងដើមទុនដែលបានបង់ ។

៦) ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត កិច្ចព្រមព្រៀងផ្សេងៗរវាងភាគទុនិកក្នុងគោលបំណងតម្រង់ទិសគោលនយោបាយរបស់ក្រុមហ៊ុនធានារ៉ាប់រង។

៧) ភាគទុនិកដែលមានសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់ពត៌មានដែលមានរៀបរាប់នៅក្នុងប្រការ ៥ នៃប្រកាសនេះ។

៨) អត្តសញ្ញាណរបស់បុគ្គល (យ៉ាងតិចពីររូប) ដែលទទួលខុសត្រូវលើដំណើរការអាជីវកម្មធានារ៉ាប់រង ឬការគ្រប់គ្រងមុខងារសំខាន់ៗ (ដូចជា មុខងារលក់ សំណង វាយតម្លៃហានិភ័យ និងគណនេយ្យ)។ អ្នកគ្រប់គ្រងទាំងនេះ ត្រូវផ្តល់ពត៌មានដែលមានចែងនៅក្នុងប្រការ៦ នៃប្រកាសនេះ ហើយប្រធានសាខារបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេសនៅកម្ពុជា ត្រូវតែងតាំងដោយអ្នកគ្រប់គ្រងដែលមានសមត្ថកិច្ចនៃទីស្នាក់ការកណ្តាល។

៩) អត្តសញ្ញាណរបស់សមាជិក ដែលមានសិទ្ធិធ្វើការសម្រេចចិត្ត និង ពត៌មានដែលតម្រូវនៅក្នុងប្រការ ៦ នៃប្រកាសនេះ។

១០) ប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជានីតិបុគ្គល ដែលបានបង្កើតរួចមកហើយ ត្រូវផ្តល់ការពិពណ៌នាអំពីអាជីវកម្មរបស់ខ្លួន និងថតចម្លងរបាយការណ៍ហិរញ្ញវត្ថុសវនកម្មបី (៣) ឆ្នាំចុងក្រោយ ។

ខ- ផែនការអាជីវកម្ម

ការពិពណ៌នាអំពីផែនការសកម្មភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ :

១) ប្រភេទ និងទំហំនៃសេវាដែលបានធានារ៉ាប់រង និងការប៉ាន់ប្រមាណអំពីតម្រូវការធានារ៉ាប់រងបន្ត។

២) ប្រភេទ និង ទំហំនៃសេវាដែលផ្តល់ចំពោះអតិថិជនផ្សេងទៀត ដូចជា ការគ្រប់គ្រងហានិភ័យ ការបង្ការការខូចខាតជាដើម។

៣) ប្រភេទអតិថិជន (បុគ្គល ក្រុមហ៊ុន អង្គការអន្តរជាតិ) ដែលក្រុមហ៊ុនធានារ៉ាប់រងចង់បាន។

៤) ប្រភេទធនធានហិរញ្ញវត្ថុគ្រោងទុក ដែលអាចជាមូលនិធិផ្ទាល់ខ្លួន បុរេប្រទានរបស់ភាគទុនិក ឥណទានធនាគារ ឬ ឥណទានផ្សេងទៀត។

៥) ចំណាយអភិវឌ្ឍន៍សម្រាប់បង្កើតក្រុមហ៊ុន។

៦) ចំនួនបុគ្គលិកសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ ដោយផ្តល់ព័ត៌មានលំអិតអំពីប្រភេទបុគ្គលិក។

៧) ចំនួន និងទីតាំងនៃការិយាល័យសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨) តារាងតុល្យការ និងរបាយការណ៍លទ្ធផលព្យាករណ៍សម្រាប់ការិយបរិច្ឆេទបី (៣)ឆ្នាំបន្តបន្ទាប់។

គ- សវនកម្មផ្ទៃក្នុង

១) រចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងដែលមានស្រាប់ និងគ្រោងទុក ដើម្បីធានាដល់ការបំពេញលក្ខខណ្ឌដែលតម្រូវដោយបទប្បញ្ញត្តិហិរញ្ញវត្ថុ។

២) វិធីសាស្ត្រក្នុងការដាក់កម្រិតលើប្រភេទហានិភ័យនីមួយៗ និង នីតិវិធីដែលបានគ្រោងទុក ដើម្បីធានាដល់ការប្រព្រឹត្តតាមច្បាប់ រួមទាំងការដាក់កម្រិតសិទ្ធិអំណាចរបស់ភ្នាក់ងារ។

៣) នីតិវិធីដែលបានគ្រោងទុក ដើម្បីបង្កើត និងធានាដល់ស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈដែលទាក់ទងនឹងសកម្មភាពលក់ និងការប្រកួតប្រជែងស្មើភាព។

៤) សមាសភាព និង ភារកិច្ចរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ឃ- សវនកម្មឯករាជ្យ

១) អត្តសញ្ញាណរបស់សវនករដែលបានស្នើឡើងត្រូវមាននៅក្នុងបញ្ជីឬត្រូវបញ្ចូលក្នុងបញ្ជីសវនករឯករាជ្យរបស់ក្រុមហ៊ុនធានារ៉ាប់រង។

២) ប្រភេទនៃការងាររបស់សវនករ។

ង- គំរូបណ្ណសន្យាធានារ៉ាប់រង

គំរូបណ្ណសន្យារ៉ាប់រង និងបណ្ណផ្សព្វផ្សាយដែលនឹងប្រើប្រាស់។

ច- លក្ខខណ្ឌបន្ថែមសម្រាប់សាខា ឬ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេស

១) ការពិពណ៌នាអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យរបស់ក្រុមហ៊ុនមេ លើសាខា ឬលើបុត្រសម្ព័ន្ធបរទេស។

២) ការពិពណ៌នាអំពីការគ្រប់គ្រងលើសាខា ឬបុត្រសម្ព័ន្ធបរទេស ដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសដើម។

៣) តារាងតុល្យការ និងរបាយការណ៍លទ្ធផលសវនកម្ម សម្រាប់រយៈពេលបី(៣)ឆ្នាំចុងក្រោយ។

៤) របាយការណ៍ហិរញ្ញវត្ថុសវនកម្មសម្រាប់រយៈពេលបីឆ្នាំដែលបានបញ្ជាក់ដោយសវនករឯករាជ្យនៃប្រទេសដើម។

៥) ការបង្ហាញពីទីតាំងនៃសាខាដែលក្រុមហ៊ុនមានបំណងបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦) លិខិតផ្តល់សិទ្ធិ ដែលបានបកប្រែស្តីពីការធ្វើអាជីវកម្មនៅក្នុងប្រទេសដើម។

៧) ពត៌មាន និងលិខិតអនុញ្ញាតពីនិយ័តករនៃប្រទេសដើមដែលបញ្ជាក់ថា ក្រុមហ៊ុនធានារ៉ាប់រងមានលទ្ធភាពទូទាត់សំណង និងបំពេញបានតាមលក្ខខណ្ឌរបស់និយ័តករ នៃប្រទេសដើមជាភាសាខ្មែរ។

៨) លិខិតតែងតាំងនីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានលក្ខណៈវិនិច្ឆ័យសមស្រប ក្នុងការគ្រប់គ្រងសាខានៅក្នុងប្រទេសកម្ពុជា។

៩) លក្ខខណ្ឌពត៌មាននៅក្នុងប្រការ ៦ ព្រមទាំងជីវប្រវត្តិសង្ខេប និង លិខិតថ្កោលទោសពីប្រទេសដើមរបស់បុគ្គលទាំងឡាយ ដែលនឹងមកគ្រប់គ្រងការិយាល័យសាខាណាមួយ។

១០) ឯកសារផ្សេងទៀតដែលតម្រូវដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៥: ភាគទុនិកដែលកាន់កាប់ដើមទុន ឬសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់

ពត៌មានដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់ភាគទុនិក

១) ក្នុងករណីជានីតិបុគ្គល : បង្ហាញឈ្មោះ ទម្រង់គតិយុត្តិ និងអាស័យដ្ឋាននៃទីស្នាក់ការកណ្តាល។

២) ក្នុងករណីជារូបវន្តបុគ្គល នាមត្រកូលនិងនាមខ្លួន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ (ឬ សញ្ជាតិទីពីរ ប្រសិនបើមាន) និងអាស័យដ្ឋាននៃប្រទេសដើម ។

៣) រាល់ភាគទុនិក ឬ អគ្គនាយកនៃនីតិបុគ្គល ត្រូវផ្តល់ជីវប្រវត្តិសង្ខេប និងបំពេញព័ត៌មាន ដែលមានចែងនៅក្នុងប្រការ ៦។

ខ- បង្ហាញចំនួន ឬ ភាគរយនៃការចូលរួមទុន ឬសិទ្ធិបោះឆ្នោតសមមូលៈ ពិពណ៌នាកិច្ចព្រមព្រៀងគតិយុត្តិ និងហិរញ្ញវត្ថុនៃការទិញមូលប័ត្រទាំងនោះ ។ ប្រសិនបើភាគទុនិក គឺជារូបវន្តបុគ្គលត្រូវបញ្ជាក់ពីប្រភពនៃដើមទុនដែលយកមកទិញមូលប័ត្រនោះ ។ បញ្ជាក់ថា តើការទិញលក់មូលប័ត្រនោះ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ឬបទប្បញ្ញត្តិឬទេដូចជា ទម្រង់ច្បាប់ដែលទាក់ទងនឹងការវិនិយោគបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- បង្ហាញពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ ប្រសិនបើមាន គួរបញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនភាគទុនិកហើយផ្តល់ ព័ត៌មានអំពីភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត។ ផ្តល់បញ្ជីឈ្មោះនៃអគ្គនាយក និងអ្នកគ្រប់គ្រង ផ្សេងទៀតរបស់ភាគទុនិក។

ឃ- ពិពណ៌នាសកម្មភាពរបស់ភាគទុនិកៈ ប្រសិនបើភាគទុនិក គឺជាផ្នែកមួយនៃសម្ព័ន្ធក្រុមហ៊ុនសូមផ្តល់ការពិពណ៌នាអំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ ព្រមទាំងរចនាសម្ព័ន្ធផ្សេងៗ ។ បង្ហាញថា តើភាគទុនិកមានភាគហ៊ុននៅក្រុមហ៊ុនធានារ៉ាប់រង ឬក្នុងស្ថាប័នធនាគារផ្សេងទៀតឬទេ ។ បង្ហាញថាតើសម្ព័ន្ធក្រុមហ៊ុនមានភាគហ៊ុននៅក្នុង ក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័ន ធនាគារឬទេ ហើយបើមានសូមបញ្ជាក់ពីភាគហ៊ុនទាំងនោះ។

ង- បង្ហាញថាតើភាគទុនិករូបនោះ និងក្រុមហ៊ុនដែលអាចពាក់ព័ន្ធទាំងឡាយ ធ្វើអាជីវកម្មធានារ៉ាប់រង និង ធនាគារឬទេ ហើយបើដូច្នោះមែន បង្ហាញពីបទប្បញ្ញត្តិ និងអាជ្ញាធរទាំងឡាយដែលពាក់ព័ន្ធ ។

ប្រការ ៦ : បុគ្គលនីមួយៗដែលបានកំណត់ក្នុងប្រការ ៤ និងជាអ្នកកាន់តំណែងគ្រប់គ្រង ដូចមានចែងនៅក្នុងប្រការ ៥ ត្រូវផ្តល់ព័ត៌មាន ជីវប្រវត្តិសង្ខេប និងគម្រូហត្ថលេខា ដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់អ្នកគ្រប់គ្រង

១) នាមត្រកូល និងនាមខ្លួន ។

២) ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ។

៣) សញ្ជាតិ ។

៤) អាស័យដ្ឋានរបស់បុគ្គល(ទីកន្លែងស្នាក់នៅ បន្ទាប់ពីទទួលការតែងតាំងនិង ក្នុងករណីមានអាស័យដ្ឋានខុសគ្នា អ្នកគ្រប់គ្រងគួរតែស្នាក់នៅទីកន្លែងធ្វើអាជីវកម្មដូចជា នៅក្នុងប្រទេស

កម្ពុជា ជាដើម) ។

ខ- ប្រវត្តិនៃការសិក្សា និង បទពិសោធន៍

១) កម្រិតវប្បធម៌ ព្រមទាំង ថ្ងៃខែឆ្នាំ និងទីកន្លែងទទួលសញ្ញាប័ត្រ ។

២) បទពិសោធន៍ការងារក្នុងរយៈពេលដប់(១០)ឆ្នាំចុងក្រោយរួមទាំង ឈ្មោះ ទីកន្លែង និងសកម្មភាពអាជីវកម្មរបស់និយោជក ប្រភេទបទពិសោធន៍ដែលទទួលបាននិងទំហំនៃការទទួលខុសត្រូវ។

គ- បង្ហាញថាតើ ក្នុងការអនុវត្តន៍ភារកិច្ច លោកអ្នកនឹងគោរពតាមការណែនាំរបស់បុគ្គល ឬក្រុមហ៊ុនផ្សេងក្រៅពីអ្នកស្នើសុំអាជ្ញាប័ណ្ណឬទេ ដែលក្នុងករណីណាក៏ដោយ សូមផ្តល់ពត៌មានដែលពាក់ព័ន្ធទាំងអស់ ។

ឃ- ពិពណ៌នាពល់កិច្ចការគ្រប់គ្រងដែលលោកអ្នកនឹងទទួលខុសត្រូវដោយផ្ទាល់ ។

ង- បង្ហាញថាតើ លោកអ្នកគឺជា ឬធ្លាប់ជាភាគទុនិកសំខាន់មួយរូប ក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយ (មានភាគហ៊ុននិងសិទ្ធិបោះឆ្នោត ចាប់ពីដប់(១០)ភាគរយ ឡើងទៅ) នៃក្រុមហ៊ុនមួយ ឬច្រើន និងចំនួនភាគហ៊ុន ដែលលោកអ្នកបានកាន់កាប់ ។

ច- បង្ហាញពីទំនាក់ទំនងរវាងក្រុមហ៊ុនដែលលោកអ្នកធ្លាប់ទទួលខុសត្រូវឬធ្លាប់មានភាគហ៊ុន និង អ្នកដាក់ ពាក្យសុំអាជ្ញាប័ណ្ណ ។

ឆ- បង្ហាញថាតើលោកអ្នកធ្លាប់ពាក់ព័ន្ធនឹងបណ្តឹងតវ៉ាផ្នែករដ្ឋបាល វិជ្ជាជីវៈ តុលាការ ដែលនាំអោយជាប់ទោសទណ្ឌផ្សេងៗ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅបរទេសដោយសូមបង្ហាញរាល់ពត៌មានលំអិតដែលពាក់ព័ន្ធ ។

ជ- បង្ហាញថា តើលោកអ្នកមានទំនាក់ទំនងល្អជាមួយម្ចាស់កម្ចី ស្ថាប័នតុលាការ ស្ថាប័នក្រៅប្រព័ន្ធតុលាការនៅកម្ពុជានិងនៅបរទេស ដើម្បីសំរួលដល់ការដោះស្រាយបំណុលដែលលោកអ្នកមិនអាចគោរពបានតាមការសន្យាពីមុនមក ។ បញ្ជាក់ថាតើលោកអ្នកដឹងអំពីបណ្តឹងណាមួយ ដែលពាក់ព័ន្ធក្រុមហ៊ុនទាំងឡាយ ដែលលោកអ្នកមានភាគហ៊ុនច្រើននៅក្នុងក្រុមហ៊ុនទាំងនោះ ដោយសូមផ្តល់រាល់ពត៌មានលំអិតដែលពាក់ព័ន្ធ ។

ឈ- បង្ហាញថាតើ លោកអ្នកធ្លាប់បានទទួលការពិន័យ ឬបណ្តេញចេញដោយនិយោជកឬទេ ហើយបើសិនជាមាន សូមផ្តល់រាល់ពត៌មានលំអិត ។

ញ- បង្ហាញថា តើលោកអ្នកមានភាគហ៊ុននៅក្នុងក្រុមហ៊ុន ដែលកំពុងដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬមានបំណងដោយផ្ទាល់ ឬតាមរយៈអន្តរការី ដើម្បីទិញយកភាគហ៊ុនពីក្រុមហ៊ុនដែលកំពុងស្នើសុំអាជ្ញា-ប័ណ្ណ ឬទេ ។

ដ- សូមផ្តល់រាល់ពត៌មានបន្ថែមជូនទៅនិយ័តករធានារ៉ាប់រងទាក់ទងនឹងសមត្ថភាព និងការកាន់តំណែងគ្រប់គ្រង នៅក្នុងក្រុមហ៊ុនដែលកំពុងសុំអាជ្ញាប័ណ្ណ ។

ជំពូក ៣ : ការអនុញ្ញាត និង សោហ៊ុយពាក់ព័ន្ធ

ប្រការ ៧ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំអាជ្ញាប័ណ្ណ រួមទាំងរាល់ឯកសារពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ការអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌពិសេសណាមួយ នឹងត្រូវផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបញ្ជាក់នូវកាលកំណត់អំពីការបំពេញលក្ខខណ្ឌនេះ។ ក្នុងករណីដែលលក្ខខណ្ឌមិនត្រូវបំពេញតាមកាលកំណត់ទេនោះ ហើយដោយពុំមានការពន្យាការអនុញ្ញាត ដោយភ្ជាប់លក្ខខណ្ឌនឹងត្រូវអស់សុពលភាពដោយឯកឯង ហើយពុំមានការចេញអាជ្ញាប័ណ្ណដូចនេះទៀតទេ។

ប្រការ ៨ : អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តបានសម្រាប់រយៈពេលបី(៣)ឆ្នាំម្តង លុះត្រាណាតែក្រុមហ៊ុនបានអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ សោហ៊ុយអាជ្ញាប័ណ្ណមានចំនួនហាសិបលាន (៥០) រៀល ។

ប្រការ ៩ : គ្រប់ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើការទូទាត់ជាកាតព្វកិច្ចទៅរាជរដ្ឋាភិបាល តាមការកំណត់ដូចខាងក្រោម :

ក) ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង់ពន្ធទៅរតនាគារជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

ខ) ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ ០,៥ភាគរយ នៃបុព្វលាភដុល ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដើម្បីទូទាត់លើចំណាយក្នុងការផ្សព្វផ្សាយសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ។

ជំពូក ៤ : ការពន្យារ និងការដកហូតអាជ្ញាប័ណ្ណ

ប្រការ ១០ : រដ្ឋមន្ត្រី អាចដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងតាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រសិនបើ :

ក) ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្ម បានបញ្ឈប់ការលក់ប័ណ្ណសន្យាធានារ៉ាប់រងថ្មីដូចបានកំណត់ឡើងក្នុងអាជ្ញាប័ណ្ណ ។

ខ) ក្រុមហ៊ុនដែលកំពុងធ្វើអាជីវកម្ម ធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់អតិថិជន ។

គ) ក្រុមហ៊ុនបាន និងកំពុងប្រព្រឹត្តល្មើសទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការធានារ៉ាប់រង និង បទប្បញ្ញត្តិដទៃទៀត ។

ឃ) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង បានផ្តល់ព័ត៌មានមិនពិតមិនជាក់លាក់ ឬបានបិទបាំង ឬមិនបង្ហាញការពិតនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណ ដែលមានចែងនៅក្នុងប្រកាសនេះ ។

ង) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្តល្មើសទៅនឹងច្បាប់ធានារ៉ាប់រង ឬបទប្បញ្ញត្តិផ្សេងទៀត ឬការប្រព្រឹត្តល្មើសដែលទាក់ទងនឹងការក្លែងបន្លំ ឬការមិនស្មោះត្រង់ដូចមានចែងនៅក្នុងច្បាប់ និងបទបញ្ញាតិជាធរមានផ្សេងៗ ។

ច) ក្រុមហ៊ុនធានារ៉ាប់រង មិនមានលទ្ធភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ឬកាតព្វកិច្ចផ្សេងទៀត ។

ឆ) ក្រុមហ៊ុនធានារ៉ាប់រង បាននិងកំពុងសម្រុះសម្រួលដោះស្រាយជាមួយម្ចាស់បំណុល ឬបានឈានចូលដល់ដំណាក់កាលដែលត្រូវជម្រះបញ្ជី ឬត្រូវបានរំលាយតាមរបៀបផ្សេងទៀត ។

ជ) ក្រុមហ៊ុនធានារ៉ាប់រង ដែលស្ថិតក្នុងករណីមានសាលក្រមរបស់តុលាការតែងតាំងឱ្យមានអ្នកមកទទួល ឬគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ ។

ឈ) កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ត្រូវបានប្រគល់ទៅឱ្យម្ចាស់បំណុល ឬអ្នកតំណាងរបស់ម្ចាស់បំណុល ទៅតាមបន្ទុកដែលមានលើទ្រព្យសម្បត្តិនោះ ។

ញ) ក្រុមហ៊ុន មិនបានធ្វើការធានារ៉ាប់រងបន្តឱ្យបានសមស្របទៅនឹងអាជីវកម្មរបស់ខ្លួន ។

ដ) ផលប្រយោជន៍របស់អ្នកប្រើប្រាស់តម្រូវអោយមានការដកហូតអាជ្ញាបណ្ណនេះ ។

ប្រការ ១១

ក) ក្នុងករណីដែលអាជ្ញាប័ណ្ណនឹងត្រូវដកហូត សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមួយដែលបញ្ជាក់អំពីមូលហេតុនៃការដកហូត នឹងត្រូវផ្ញើរជូនទៅក្រុមហ៊ុនធានារ៉ាប់រងនោះ ។

ខ) ក្រុមហ៊ុន ត្រូវបានផ្តល់ឱកាសអោយឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ។

គ) ក្នុងករណីដែលនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មិនបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងចំណុច (ខ) រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច នឹងហិរញ្ញវត្ថុ នឹងដកហូតអាជ្ញាប័ណ្ណតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ ។

ឃ) ក្នុងករណីដែលបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ បន្ទាប់ពីមានការពិចារណាលើការឆ្លើយតបនេះ ក្រសួងនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្ត ។

ង) ក្នុងករណីដែលក្រសួងសម្រេចថា មិនដកហូតអាជ្ញាប័ណ្ណទេនោះ ការដាក់លក្ខខណ្ឌទៅលើការបន្តអនុវត្តអាជ្ញាប័ណ្ណនឹងធ្វើឡើងតាមរយៈសេចក្តីជូនដំណឹង ។

ប្រការ ១២ : ក្រុមហ៊ុនដែលមិនពេញចិត្តចំពោះការដកហូតអាជ្ញាប័ណ្ណ អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនោះទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសំរេចនេះ ។

ប្រការ ១៣ : រដ្ឋមន្ត្រី និងមន្ត្រីនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលបំពេញការងារតាមការណែនាំរបស់រដ្ឋមន្ត្រី ឬនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នឹងមិនអាចត្រូវប្តឹងចំពោះការបំពេញ

មុខងារ និងភារៈកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងប្រការ ១០ នៃប្រកាសនេះ ប្រសិនបើការបំពេញការងារនោះ ត្រូវបានធ្វើឡើងសុចរិតភាព ។

ជំពូក ៥ : បទប្បញ្ញត្តិផ្សេងទៀត

ប្រការ ១៤ : កាលណាមានការទិញយកភាគហ៊ុននៅក្នុងក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើឱ្យភាគទុនិកកើនចាប់ពីដប់(១០) ភាគរយនៃភាគហ៊ុនរបស់ក្រុមហ៊ុនឡើងទៅ ភាគទុនិកនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប និងភ្ជាប់មកជាមួយនូវកម្រងសំណួរ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងប្រភពនៃដើមទុន ដែលប្រើសម្រាប់ទិញភាគហ៊ុននោះ។ ភាគហ៊ុនដែលបានទិញដោយមិនមានការឯកភាពជាមុននឹងមិនផ្តល់នូវសិទ្ធិអំណាច ឬការទទួលស្គាល់នោះទេ ដរាបណាមិនទាន់បានទទួលការឯកភាព ។

ប្រការ ១៥ : ក្នុងករណីមានការតែងតាំងអគ្គនាយកថ្មី ឬមានការផ្លាស់ប្តូរបុគ្គលទាំងឡាយណា (មានបញ្ជាក់នៅក្នុងប្រការ ៤) ដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព បុគ្គលដែលត្រូវតាំងថ្មីទាំងនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប ដោយភ្ជាប់មកជាមួយនូវកម្រងសំណួរ ដែលបានចែងនៅក្នុងប្រការ ៦ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែ ក្នុងករណីដែលមានការតែងតាំង ឬការជំនួសជាបន្ទាន់ ក្រុមហ៊ុនត្រូវផ្តល់ឯកសារទាំងនោះ អោយបានមួយ(១)ខែមុនពេលដែលបុគ្គលនោះចូលកាន់តំណែង ។

ប្រការ ១៦ : ប្រសិនបើ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ រកឃើញថាបុគ្គលទាំងឡាយណា ដែលកំពុងបម្រើការងារជាអគ្គនាយក ឬបុគ្គលដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព មិនមានសមត្ថភាព ឬមិនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ក្នុងការកាន់តំណែងនោះទេ នាយកដ្ឋានអាចបញ្ជាឱ្យដកបុគ្គលនោះពីតំណែង ក្នុងរយៈពេលមួយដែលកំណត់នៅក្នុងលិខិតដោយឡែកមួយ ។ ក្នុងករណីដែលក្រុមហ៊ុនជឿជាក់ថាការបញ្ជាឱ្យដកតំណែងនោះ មានមូលដ្ឋានលើព័ត៌មានមិនពិត ឬជាការភាន់ច្រឡំ អាចប្តឹងជំទាស់នឹងលិខិតបញ្ជានេះ ទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ដប់ (១០)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតបញ្ជានោះ។ ប្រសិនបើ រដ្ឋមន្ត្រីឯកភាពជាមួយនឹងការចេញលិខិតបញ្ជានោះ ក្នុងរយៈពេលដប់(១០)ថ្ងៃ គិតចាប់ពីថ្ងៃប្តឹងជំទាស់ លិខិតបញ្ជានោះនឹងត្រូវចូលជាធរមាន។

ប្រការ ១៧ : ក្រុមហ៊ុន ត្រូវជូនដំណឹងនូវរាល់ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តិ និងហិរញ្ញវត្ថុ ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសុំការអនុម័ត ។ ឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវការពិពណ៌នាអំពីមូលហេតុនៃការផ្លាស់ប្តូរប្រតិបត្តិការ ដោយរួមមានព័ត៌មានដូចតទៅ :

ក) ការពង្រីក ឬការកែប្រែសកម្មភាព : ត្រូវផ្តល់ព័ត៌មានដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១១ នៃ

ប្រការ ៤ នៃប្រកាសនេះ ។

ខ) ការបន្ថយដើមទុន : ការពិពណ៌នាពីលក្ខខណ្ឌដូចជា លក្ខខណ្ឌគតិយុត្តិ និងគណនេយ្យ ហើយ និងការបង្ហាញតួលេខថ្មីនៃមូលនិធិផ្ទាល់ ព្រមទាំងផលប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្ម នាពេលអនាគត និងអនុបាតប្រុងប្រយ័ត្ន ។

គ) ការផ្លាស់ប្តូរទម្រង់គតិយុត្តិ : សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន និង ពត៌មានដែល ពាក់ព័ន្ធនឹងគណៈគ្រប់គ្រង។

ឃ) ការផ្លាស់ប្តូរប្រភេទអាជីវកម្ម : សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន

ក្រុមហ៊ុនត្រូវរាយការណ៍នូវរាល់ការផ្លាស់ប្តូរទាំងអស់នេះ ដល់នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងហោចណាស់ពីរ(២)ខែ មុនពេលដែលការ ផ្លាស់ប្តូរកើតឡើង បើពុំនោះទេ សម្រាប់រយៈពេលជូនដំណឹងខ្លីជាងនេះ ត្រូវមានការឯកភាពពី នាយកដ្ឋាន ឧស្សាហកម្មហិរញ្ញវត្ថុ ។

ប្រការ ១៨ : ក្រុមហ៊ុនធានារ៉ាប់រង ដែលទទួលបានអាជ្ញាប័ណ្ណ អាចបើកសាខាការិយាល័យក្នុងស្រុកនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយគ្រាន់តែមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុណ្ណោះ ។

ប្រការ ១៩ : បុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការដាក់ពិន័យជាប្រាក់ ចំនួន ១០លានរៀល បង់ចូលរតនាគារជាតិ ។

ប្រការ ២០ : ប្រកាសលេខ ៨៦៤ សហវ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ត្រូវទុកជានិរាករណ៍ ។ បទប្បញ្ញត្តិ ដទៃទៀតណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ដែរ ។

ប្រការ ២១ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងសាធារណការនិងដឹកជញ្ជូន

លេខ : ១០០សហវ.ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពី
ការគ្រប់គ្រងរថយន្តចង្កូតស្តាំ ដែលមានស្រាប់នៅក្នុងប្រទេស

*** ***

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងសារាចរលេខ ០២ ស.រ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេស
- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ លើលិខិតលេខ ៧៨២២ សហវ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីករណីពាក់ព័ន្ធនឹងការប្រមូលពន្ធនិងអាករលើយានយន្តចង្កូតស្តាំគ្រប់ប្រភេទដែលកំពុងចរាចរនៅក្នុងស្រុក
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន /

សំរេច

ប្រការ ១: មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត- ក្រុង ព្រមទាំងអង្គភាពមានសមត្ថកិច្ចនៃក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវធ្វើការចុះបញ្ជីយានយន្ត និងផ្តល់ផ្លាកលេខរថយន្តចង្កូតស្តាំគ្រប់ប្រភេទ ដែលមានស្រាប់ក្នុងប្រទេស ហើយដែលបានបំពេញកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវរួចហើយ ឱ្យមានសិទ្ធិធ្វើចរាចរដោយស្របច្បាប់លើផ្លូវសាធារណៈ។

ប្រការ ២: នីតិវិធីក្នុងការចេញផ្លាកលេខជូនរថយន្តចង្កូតស្តាំនេះ អនុវត្តចំពោះតែរថយន្តចង្កូតស្តាំទាំងឡាយណាដែលមានបង្កាន់ដៃពន្ធនាំចូលដែលមានការពិនិត្យ និងបញ្ជាក់ត្រឹមត្រូវពីទីចាត់ការគយនិងរដ្ឋាករ។ ក្នុងករណីដែលមន្ត្រីមានសមត្ថកិច្ចដូចរៀបរាប់ក្នុងប្រការ ១ ខាងលើ ពិនិត្យឃើញថា ការបង់ពន្ធយានយន្តណាមួយមានលក្ខណៈពុំត្រឹមត្រូវដោយប្រការណាមួយ ម្ចាស់យានយន្តទាំងនោះត្រូវចូលខ្លួនមកទីចាត់ការគយនិងរដ្ឋាករ ដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធឱ្យបានត្រឹមត្រូវតាមការកំណត់ឡើងវិញ ចៀសវាងនូវការយឺតយ៉ាវដោយថាហេតុក្នុងការផ្តល់ផ្លាកលេខជូន។

ប្រការ ៣: ម្ចាស់រថយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេស ហើយពុំទាន់មានលទ្ធភាពបំពេញកាតព្វកិច្ចពន្ធ អាករនាំចូលនៅឡើយនោះ ត្រូវរួសរាន់ចូលខ្លួនមកប្រកាសចុះបញ្ជីយានយន្តចង្កូតស្តាំរបស់ខ្លួននៅតាមគ្រប់សាខា ការិយាល័យ ឬទីស្នាក់ការគយនិងរដ្ឋាករនៅទូទាំងប្រទេស ដែលនៅជិតលំនៅដ្ឋានរបស់ខ្លួនចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧ ជាកំហិត។ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៧ ម្ចាស់យានយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេសទាំងអស់ អាចបំពេញកាតព្វកិច្ចពន្ធនៅការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ តាមសាខាគយនិងរដ្ឋាករខេត្ត- ក្រុង និងនៅទីស្នាក់ការគយនិងរដ្ឋាករតាមខណ្ឌទាំងអស់របស់សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ បានតែក្នុងករណីដែលរថយន្តចង្កូតស្តាំទាំងនោះមានចុះបញ្ជីរួចរាល់ប៉ុណ្ណោះ។

ប្រការ ៤: យានយន្តចង្កូតស្តាំទាំងឡាយណាដែលពុំបានចុះបញ្ជី ឬពុំបានបំពេញកាតព្វកិច្ចពន្ធតាមកាលកំណត់ខាងលើនេះ នឹងត្រូវចាត់ទុកជារថយន្តដែលនាំចូលក្រោយថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៦ រំលោភលើស្មារតីសារាចរលេខ ០២ សរ ដូចយោងខាងលើ និងមិនត្រូវបានអនុញ្ញាតឱ្យបំពេញកាតព្វកិច្ចពន្ធ អាករទៀតឡើយ ហើយត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន និងបញ្ជូនករណីនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

ប្រការ ៥: អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន និងទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងចំណុចទំនាក់ទំនង (Focal Point) មួយដែលមានការចូលរួមពីមន្ត្រី ០៣(បី)រូប ពីស្ថាប័ននីមួយៗ ដើម្បីធ្វើការផ្លាស់ប្តូរពត៌មាន ឬដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើងដោយថាហេតុ ក្នុងដំណើរការអនុវត្តប្រកាសអន្តរក្រសួងនេះ និង

សហការគ្នាឱ្យបានល្អ លុបបំបាត់នូវអំពើល្មើសអសកម្ម រំលោភបំពានលើការហាមឃាត់របស់រាជរដ្ឋាភិបាលកន្លងមក។

ប្រការ ៦: អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន ទីចាត់ការគយនិងរដ្ឋាករ និងនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ចែងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានាដល់មហាជនគ្រប់ស្រទាប់ឱ្យបានយល់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់ និងចូលរួមអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ ៧: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ ប្រធាននាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន នាយកមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ស៊ុន ចាន់ថុល

<u>ចម្លងជូន</u> :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- "ដើម្បីជូនជ្រាបជាពតិមាន"
- គ្រប់សាលាខេត្ត- ក្រុង
  "ដើម្បីជូនជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- គ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត- ក្រុង
- គ្រប់សាខា ការិយាល័យ និងទីស្នាក់ការគយនិងរដ្ឋាករពាក់ព័ន្ធ
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០២.....សហវ.....

គណៈកម្មការអន្តរក្រសួង

ភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៧

សេចក្តីណែនាំ
ស្តីពី
ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រធាន និងសមាជិកក្រុមការងាររបស់គណៈកម្មការអន្តរក្រសួង

ឆ្លងតាមការអនុវត្តន៍ការងារ Resettlement នៃគំរោងអភិវឌ្ឍន៍នានា បានបង្ហាញអោយឃើញថា ការងារ Resettlement នាពេលបច្ចុប្បន្ន និងអនាគត មានភាពស្មុគស្មាញ និងបញ្ហាប្រឈមជាងការងារនាពេលកន្លងមក ។ ក្រោមការណែនាំ ការដាស់តឿន ការលើកទឹកចិត្តពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការអន្តរក្រសួង បានរៀបចំវិធានការដំបូង ដើម្បីជំនះនូវបញ្ហាប្រឈមទាំងនេះ ។ វិធានការនោះ សំដៅពង្រឹងភាពភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមការងាររបស់គណៈកម្មការអន្តរក្រសួងដែលបាន និងកំពុងអនុវត្តការងារ Resettlement នៅតាមទីតាំងនៃគំរោងនីមួយៗ ។

កាលពីពេលថ្មីៗនេះ គណៈកម្មការអន្តរក្រសួង បានសង្កេតឃើញថា ការអនុវត្តន៍ការងាររបស់ក្រុមការងារនៃគណៈកម្មការអន្តរក្រសួងនៅទីកន្លែងដែលគំរោងស្ថិតនៅ ពុំទាន់បានឆ្លើយតបទៅតាមតំរូវការជាក់ស្តែង និងប្រសិទ្ធភាពការងារ ពោលគឺអភិបាលកិច្ចល្អ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលបានទាំងស្រុងនៅឡើយ ។ ការអនុវត្តន៍ការងារ Resettlement ក្រោមគំរោងអភិវឌ្ឍន៍នីមួយៗ មានចរិតលក្ខណៈខុសគ្នាផ្អែកទៅតាមទីតាំង និងប្រភេទនៃគំរោងនីមួយៗ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មានការងារ Resettlement ខ្លះ បានអូសបន្លាយពេលវេលាដែលបណ្តាលអោយប្រសិទ្ធភាពការងារនៅមានកំរិត និងចំណាយថវិកាលើការអនុវត្តន៍ការងារមានការកើនឡើង ។ ផ្តើមចេញពីភាពអវិជ្ជមានមួយចំនួននេះ និងក្នុងគោលដៅបង្កើនវប្បធម៌ប្រសិទ្ធភាពការងារ សន្សំសំចៃធនធាន ពេលវេលាធ្វើការប្រកបដោយវិន័យ ឆ្លើយតបនឹងការផ្តល់ទំនុកចិត្តរបស់រាជរដ្ឋាភិបាល គណៈកម្មការអន្តរក្រសួងសូមធ្វើការណែនាំដូចខាងក្រោមៈ

១- អំពីការងារ

តាមការអនុវត្តន៍ជាក់ស្តែងនៃគំរោងអភិវឌ្ឍន៍ទាំងឡាយ សមាសភាពនៃក្រុមការងារ មានការចូលរួមមកពីបណ្តាក្រសួងពាក់ព័ន្ធដូចមានចែងក្នុងសមាសភាពនៃគណៈកម្មការអន្តរក្រសួង ។ ក្រុមការងារនៃគណៈកម្មការអន្តរក្រសួង ដោយសហការជាមួយអនុគណៈកម្មការខេត្ត-ក្រុង ត្រូវបានបង្កើតឡើង ដើម្បីចុះអនុវត្តការងារ Resettlement នៃគំរោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដែលជារួមមាន ការចុះពិគ្រោះយោបល់ជាសាធារណៈ ការធ្វើអង្កេតវាស់វែង លំអិត ការចុះកិច្ចសន្យាជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងការទូទាត់ប្រាក់សំណងជូនប្រជាពលរដ្ឋទាំងនោះ ។

២- អំពីការធ្វើផែនការ និងការប្រតិបត្តិរបស់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារនេះ

- ប្រធានក្រុមការងារ ត្រូវរៀបចំផែនការ និងកម្មវិធីការងារអោយបានច្បាស់លាស់មុនពេលចុះអនុវត្តការងារនៅតាមទីកន្លែងដែលគំរោងស្ថិតនៅ ។

- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវអនុវត្តការងារអោយបានម៉ឺងម៉ាត់ទៅតាមផែនការការងារដែលបានដាក់ចេញ ។
- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវគោរពពេលម៉ោងធ្វើការអោយបានត្រឹមត្រូវ គឺពេលព្រឹកពីម៉ោង ៧:៣០ ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់ និងពេលល្ងាចពីម៉ោង ១:៣០ ដល់ ម៉ោង ៥:៣០ ល្ងាច ។
- មិនត្រូវបានអនុញ្ញាតអោយសេពគ្រឿងស្រវឹងក្នុងពេលអនុវត្តការងារ ។
- រាល់ការឈប់សំរាក ត្រូវសុំការអនុញ្ញាតច្បាប់ពីប្រធានក្រុមការងារ ។ ច្បាប់អនុញ្ញាត មិនត្រូវបានផ្តល់ជូនលើសពី បីថ្ងៃក្នុងមួយខែ ឡើយ ។
- រាល់អវត្តមានដោយគ្មានការអនុញ្ញាត មិនត្រូវទទួលបានប្រាក់ឧបត្ថម្ភឡើយ ។
- ប្រធាន អនុប្រធាន និងសមាជិក ត្រូវរកទីតាំងស្នាក់នៅដែលប្រកបដោយអំណោយផលដល់ការអនុវត្តន៍ការងារ ដោយមិនត្រូវស្ថិតនៅឆ្ងាយជាង ២៥ គ.ម ពីទីតាំង អនុវត្តគំរោងឡើយ ។
- ប្រធាន អនុប្រធាន និងសមាជិក ត្រូវអនុវត្តការងារអោយមានប្រសិទ្ធភាពតាមការណែនាំ និងផែនការដែលថ្នាក់ដឹកនាំបានប្រគល់ជូន ។ រាល់ការអនុវត្តន៍ផ្ទុយពីការណែនាំ និងគោលការណ៍របស់រាជរដ្ឋាភិបាលក្នុងគោលបំណងបំរើប្រយោជន៍ផ្ទាល់ខ្លួន ប្រធាន អនុប្រធាន និងសមាជិក ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។
- ប្រធានក្រុម បន្ទាប់ពីបានការអនុញ្ញាតច្បាប់តាមរយៈអង្គភាពពីថ្នាក់ដឹកនាំស្ថាប័ន ត្រូវផ្ទេរភារកិច្ចជូនអនុ-ប្រធាន ក្នុងករណីដែលខ្លួនមានធុរៈចាំបាច់ ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសរហូតដល់ថ្ងៃត្រឡប់ចូលធ្វើការវិញ ។ ការផ្ទេរភារកិច្ចជូនអនុប្រធានត្រូវជូនដំណឹងដល់មន្ត្រីក្នុងក្រុម ។
- ប្រធាន និងអនុប្រធានត្រូវយល់អោយច្បាស់ពីគោលនយោបាយ និងនិតិវិធីដោះស្រាយផលប៉ះពាល់ដូចមានចែង និងព្រមព្រៀងនៅក្នុងសៀវភៅផែនការសកម្មភាព សំរាប់ការតាំងទីលំនៅឡើងវិញ (Resettlement Action Plan, RAP) ដើម្បីណែនាំសមាជិកក្រុមការងារអោយយល់ច្បាស់ មុនពេលចុះអនុវត្ត ។
- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារទាំងអស់ ត្រូវអនុវត្តអោយបានខ្ជាប់ខ្ជួនតាមគោលការណ៍ និងនិតិវិធីនៅក្នុង RAP ។
- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារទាំងអស់ត្រូវពាក់ប័ណ្ណសំគាល់ខ្លួននៅពេលចុះអនុវត្តការងារ ។

៣- អំពីការរៀបចំ និងការអនុវត្តន៍ការងារប្រចាំថ្ងៃ:

ប្រធានក្រុមការងារត្រូវ:

- រៀបចំធ្វើបញ្ជីវត្តមានប្រចាំថ្ងៃ ។ ក្នុងករណីមន្ត្រីណាមួយ ឈប់លើសពីមួយសប្តាហ៍ក្នុងមួយខែ ត្រូវបញ្ឈប់ពីការងារដោយស្វ័យប្រវត្តិ ។
- រៀបចំកម្មវិធីការងារប្រចាំថ្ងៃជូនអនុប្រធាន និងសមាជិកក្រុមការងារដើម្បីអោយអនុវត្ត ផ្អែកតាមផែន-ការមេ ដែលបានដាក់ចេញដោយថ្នាក់ដឹកនាំ ។
- ដឹកនាំ និងគ្រប់គ្រងក្រុមការងារលើការអនុវត្តន៍តាមកម្មវិធីការងារនេះ ។
- ត្រួតពិនិត្យឡើងវិញ ដោយធ្វើការផ្ទៀងផ្ទាត់រវាងកញ្ចប់ការងារដែលបានដាក់ចេញ និងលទ្ធផលការងារដែលទទួលបានប្រចាំថ្ងៃ ។
- ក្នុងករណីចាំបាច់ ត្រូវធ្វើការពិភាក្សាក្នុងក្រុមការងារដើម្បីដោះស្រាយរាល់ការលំបាក និងបញ្ហាប្រឈមផ្សេងៗ ដែលកើតមានឡើងក្នុងការអនុវត្តន៍ការងារប្រចាំថ្ងៃ ។ ក្នុងករណីមិនអាចដោះស្រាយបាន ក្នុងក្របខ័ណ្ឌក្រុមការងារគណៈកម្មការអន្តរក្រសួង ត្រូវលើកយកបញ្ហាទាំងនោះ ធ្វើការពិភាក្សាបន្ទាន់ជាមួយអនុគណៈកម្មការខេត្ត ។ បើបញ្ហានៅតែមិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំដើម្បីរកដំណោះស្រាយសមស្រប ។
- របបការងារប្រចាំថ្ងៃត្រូវមានលក្ខណៈជាប្រព័ន្ធ ប្រធាន អនុប្រធាន និងសមាជិក ត្រូវអនុវត្តការងារតាមតួនាទី និងតាមឋានានុក្រម ។

៤- អំពីការសហការជាមួយសមាជិកក្រុមការងារខ្លួនឯង និងអាជ្ញាធរមូលដ្ឋាន

- ប្រធានក្រុមការងារ ត្រូវមានរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ ដើម្បីធ្វើការបូកសរុបលទ្ធផលការងារដែលទទួលបានធៀបទៅនឹងផែនការដែលបានដាក់ចេញ ព្រមទាំងធ្វើសំណូមពរសុំអោយក្រុមការងារអនុគណៈកម្មការបន្តសហការជំរុញការងារដែលជាសមត្ថកិច្ចរបស់អាជ្ញាធរដែនដីផ្ទាល់ ។
- ក្រុមការងាររបស់គណៈកម្មការអន្តរក្រសួង ត្រូវរក្សាកិច្ចសហការល្អជាមួយអនុគណៈកម្មការខេត្ត ដើម្បីជំរុញការអនុវត្តន៏ការងារដោះស្រាយផលប៉ះពាល់ដោយសារគំរោងកាន់តែមានប្រសិទ្ធភាពខ្ពស់ ។
- សម្របសម្រួលជាមួយអនុគណៈកម្មការខេត្ត ក្នុងការរៀបចំកិច្ចប្រជុំរវាងគណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការខេត្ត ។
- ជូនដំណឹងដល់ក្រុមការងារអនុគណៈកម្មការខេត្ត អំពីកាលបរិច្ឆេទចុះអនុវត្តការងារ និងផែនការការងារដែលបានលើកឡើង ។

៥- អំពីការធ្វើរបាយការណ៍ស្តីពីដំណើរការនៃការអនុវត្តន៏ការងារ

- ក្រុមការងារ ត្រូវមានរបាយការណ៏ប្រចាំថ្ងៃ ស្តីពីលទ្ធផលការងារដែលអនុវត្តបានក្នុងថ្ងៃនីមួយៗ ហើយផ្ញើលទ្ធផលការងារនេះ មកលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង (អង្គភាព Resettlement នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈទូរសារ ឬមធ្យោបាយផ្សេងៗទៀត) ។
- ក្រុមការងារ ត្រូវបញ្ចូលទិន្នន័យដែលប្រមូលបានជាបណ្តើរៗពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ ។
- ក្រុមការងារ ត្រូវធ្វើរបាយការណ៏ប្រចាំសប្តាហ៍ស្តីពីវឌ្ឍនភាពនៃការងារ Resettlement ។
- យ៉ាងយូរមួយសប្តាហ៏ បន្ទាប់ពីថ្ងៃបញ្ចប់ការងារនៅទីតាំងដែលគំរោងស្ថិតនៅ ទិន្នន័យផលប៉ះពាល់ ត្រូវរៀបចំអោយបានរួចរាល់ ព្រមទាំងភ្ជាប់របាយការណ៏បញ្ចប់ការងារអង្កេតវាស់វែងលំអិត សំរាប់ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសំរេច ។

